# នីតិវិធីនៃការសង្គ្រោះសត្វព្រៃ ចាប់កាន់សត្វព្រៃ និងលែងសត្វព្រៃ





WWF

ANGKOR CENTRE FOR CONSERVATION OF BIODIVERSITY
ACCB
A KINGDOM OF CAMBODIA/GOETZ-PROJECT

ALLWETTERZOO MÜNSTER

WTG
Welttierschutzgesellschaft e.V.

# នីតិវិធីនៃការសង្គ្រោះសត្វព្រៃ ចាប់កាន់សត្វព្រៃនិងលែងសត្វព្រៃ

## មគ្គុទ្ទេសក៍សម្រាប់ព្រះសង្ឃពុទ្ធសាសនា នៅប្រទេសកម្ពុជា

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការ WWF  និងអង្គការ WTG ដែលបានចូលរួមឧបត្ថម្ភថវិកាដើម្បីបោះពុម្ពសៀវភៅនេះឡើង



**សៀវភៅនេះរៀបរៀងឡើងដោយៈ**

ជិម សុភាព
ជូលៀ ស្តេនខាត់
គ្រីសតែល ហ្វ្រិហ្វីយ៉ូន
វ៉ាន់ សុជា

រក្សាសិទ្ធិដោយមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ និងអង្គការ WWF © ឆ្នាំ២០២១

# មាតិកា


- សេចក្តីផ្តើម៖........................................................................................................១
  - មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ ( ACCB )..................................................១
  - ហេតុអ្វីបានជា ACCB សង្គ្រោះសត្វព្រៃ.................................................................................២
- ផ្នែកទី ១៖ ការរក្សាទុកសត្វព្រៃនៅតាមផ្ទះគឺជាអំពើខុសនឹងច្បាប់...................................................៤
- ផ្នែកទី ២៖ សុវត្ថិភាពជាចំបង!......................................................................................................៥
  - ពួកសត្វមានពិស៖ ពស់.........................................................................................................៦
  - ពួកសត្វមានពិស៖ ញើ.......................................................................................................១០
  - ជំងឺឆ្លងហ្សូណូស (ZOONOSES)៖ ជំងឺឆ្លងរវាងមនុស្សនិងសត្វ..............................................១២
  - ឧទាហរណ៍៖ ជំងឺអែប៉េសប្រភេទបេ (HERPES B) ឆ្លងពីវីរុសផ្ទុកក្នុងខ្លួនពួកសត្វស្វា..........................១៣
  - ឧទាហរណ៍៖ ជំងឺផ្តាសាយបក្សី.............................................................................................១៤
  - ឧទាហរណ៍៖ ប៉ារ៉ាស៊ីតបក្សី (មេរោគព្រូនល្អិតៗ) ដ៏សាមញ្ញមួយចំនួន....................................................១៥
  - ឧទាហរណ៍៖ ជំងឺឆ្កែឆ្កួត.....................................................................................................១៦

# មាតិកា


- ឧទាហរណ៍៖ ជំងឺសាល់ម៉ូណេឡា (SALMONELLA) ឆ្លងពីបាក់តេរីផ្ទុកក្នុងខ្លួនពួកសត្វល្មូន..................................១៧
- ឧទាហរណ៍៖ ជំងឺដង្កូវព្រូនទ្រីស៊ីណែឡា (TRICHINELLA)...........................................................................១៨
- វិធានទូទៅដើម្បីជៀសវាងពីជំងឺឆ្លងហ្សូណូស (ZOONOSES)៖ ជំងឺឆ្លងរវាងមនុស្សនិងសត្វ..................................១៩
- សម្ភារៈចាំបាច់មួយចំនួនដែលអ្នកត្រូវមានក្នុងពេលចាប់កាន់សត្វព្រៃ.........................................................២០
- ការរងរបួសដែលបង្កដោយសារសត្វព្រៃ៖ របួសស្នាមដោយសារសត្វខាំនិងខ្វាច.................................................២១
- ផ្នែកទី ៣៖ បច្ចេកទេសចាប់កាន់សត្វព្រៃ (ចាប់កុំឱ្យរើខ្លួនរួច) ចំពោះប្រភេទសត្វដែលអ្នកតែងតែជួបប្រទះ...................២២
  - តើសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) អាចធ្វើឱ្យសត្វស្លាប់បានដោយវិធីណា៖ ជំងឺសាច់ដុំ...................................២៣
  - ការចាប់កាន់ពួកសត្វមំសាសីថ្នាក់តូច៖ ភេ សំពោច ឆ្មាដាវ.......................................................................២៥
  - ការចាប់កាន់ពួកសត្វប្រមា.........................................................................................................២៧
  - ការចាប់កាន់ពួកសត្វពានរ៖ ក្រុមស្វាព្រាម ស្វាក្តាមនិងទោច.......................................................................២៨
  - ការចាប់កាន់ពួកសត្វចតុប្បាទ៖ ក្រុមតិណាសីថ្នាក់តូច(រមាំង ប្រើស) និងជ្រូកព្រៃ គោក្របីព្រៃ..................................២៩
  - ការចាប់កាន់ពួកសត្វចតុប្បាទ៖ ក្រុមតិណាសីថ្នាក់តូច(ឈ្លូស ក្តាន់ ក្តាន់ញៀងតូច)..........................................៣០

# មាតិកា


- ការចាប់កាន់ពួកសត្វស្លាបៈ វិធានទូទៅ..........ពី១
- ការចាប់កាន់ពួកសត្វពស់..........៣៧
- ការចាប់កាន់ពួកសត្វអន្សង់ ត្រកួតនិងក្រពើតូចៗ..........៣៩
- សត្វជាប់អន្ទាក់..........៤០
- ផ្នែកទី ៤៖ ការផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ..........៤២
  - ទ្រុងដែលសមស្របសម្រាប់ផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូន..........៤៣
  - ជៀសវាងសភាពតានតឹងផ្លូវចិត្ត(ជំងឺស្ត្រេស) និងហានិភ័យផ្សេងៗ..........៤៦
  - ការផ្តល់ចំណីអាហារនិងទឹកដល់សត្វព្រៃ..........៤៩
- ផ្នែកទី ៥៖ អ្វីដែលត្រូវធ្វើក្រោយពេលទទួលបានសត្វព្រៃ ឬ បន្ទាប់ពីបានជួយសង្គ្រោះសត្វព្រៃរួចហើយ..........៥០
  - សំណួរទី ១៖ តើសត្វប្រភេទនោះមានដើមកំណើតនៅប្រទេសកម្ពុជា ឬ មិនមែនទេ?..........៥១
    - តើមានបញ្ហាអ្វីកើតឡើងប្រសិនបើលែងប្រភេទសត្វដែលមិនមានដើមកំណើតនៅប្រទេសកម្ពុជា..........៥២

# មាតិកា


- ជំងឺរាតត្បាតមួយប្រភេទ៖ ឧទាហរណ៍ជំងឺផ្សិតទ្រីឌីអូមីកូស៊ីស (CHYTRID FUNGUS)........................................៥៣
- ប្រភេទរាតត្បាតមួយចំនួនដែលបានមកដល់ប្រទេសកម្ពុជា ហើយបានបង្កបញ្ហាជាច្រើនរួចទៅហើយ........................៥៥
- តើប្រភេទសត្វរាតត្បាតសំខាន់ៗណាខ្លះដែលអ្នកឧស្សាហ៍ជួបប្រទះ..................................................................៥៧
- ប្រភេទរាតត្បាត៖ ឧទាហរណ៍ពួកសត្វសេក ALEXANDRINE PARAKEET (PSITTACULA EUPATRIA)..............៥៩
- សំណួរទី ២៖ តើសត្វនោះ ត្រូវបានចិញ្ចឹមអស់រយៈពេលយូរប៉ុនណាហើយ?.........................................................៦០
- ហេតុអ្វីសត្វដែលចិញ្ចឹមអស់រយៈពេលយូរ មិនអាចលែងបានភ្លាមៗ?.....................................................................៦១
- សំណួរទី ៣៖ តើសត្វនោះនៅក្មេង(កូនសត្វ) ឬ ធំពេញវ័យហើយ?.......................................................................៦៣
- ហេតុអ្វីបានជាកូនសត្វ ជាធម្មតាមិនអាចលែងភ្លាមៗបាន?...................................................................................៦៤
- សំណួរទី ៤៖ តើសត្វនោះមានសុខភាពល្អ ហើយគ្មានរបួសដែរឬទេ?.................................................................៦៦
- វិធីសម្គាល់សត្វមានជំងឺ?...........................................................................................................................................៦៨
- សត្វឈើ៖ ពួកសត្វអណ្តើកទឹកនិងអណ្តើកគោកពុកស្នូក........................................................................................៧៣

# មាតិកា

- សត្វឈើ៖ ពួកសត្វស្លាបដាច់ដោចរោម........................................................................................៧៥
- សត្វឈើ៖ ពួកសត្វដែលត្រូវបានគេកាត់ធ្មេញ ឬ ចង្កូមចេញ....................................................................៧៦
- សំណួរទី ៥៖ តើសត្វនោះខ្លាចមនុស្សដែរឬទេ ?.....................................................................................៧៧
- ឧទាហរណ៍: ការប៉ះទង្គិចគ្នារវាងមនុស្សនិងពួកសត្វស្វា ដែលបានបង្កឡើងដោយពួកសត្វស្វាស៊ាំតាមទម្លាប់របស់មនុស្ស ?..............................................................................................................................................៨១
- សំណួរទី ៦៖ តើយើងអាចលែងសត្វនោះភ្លាមៗទៅក្នុងជម្រកសមស្របណាមួយបានដែរឬទេ ?..........................៨៣
- ផ្នែកទី ៦៖ ចំណុចមួយចំនួនដែលត្រូវពិចារណាមុនពេលលែងសត្វត្រឡប់ទៅក្នុងព្រៃធម្មជាតិវិញ..............................៨៥
  - តើកន្លែងបែបណា ជាទីតាំងលែងសត្វដែលសមស្របនិងមានសុវត្ថិភាព ?...................................................៨៦
  - ពេលវេលាប្រចាំថ្ងៃ (ម៉ោងណា ពេលណា ថ្ងៃ ឬ យប់ ? ) និងស្ថានភាពអាកាសធាតុ ?..................................៨៩
  - ពេលវេលាប្រចាំឆ្នាំ (ខែណា ឬ រដូវណា ? )..............................................................................................៩០
  - ការលែងសត្វ៖ អ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ........................................................................................៩១

# សេចក្តីផ្តើម៖
# មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB)

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) គឺជាមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃនិងអភិរក្សជីវៈចម្រុះមួយ ដែលមានទីតាំងស្ថិតនៅជើងភ្នំក្បាលស្ពាន (ឧទ្យានជាតិភ្នំគូលែន)។ ACCB មានគោលបំណងសំខាន់ដើម្បីចូលរួមចំណែកដល់ការសង្គ្រោះសត្វព្រៃនិងការអភិរក្សជីវៈចម្រុះនៅប្រទេសកម្ពុជា។ គំនិតផ្តួចផ្តើមបង្កើតមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃនៅក្បែរឧទ្យានជាតិអង្គរមានប្រភពដំបូងបង្អស់មកពីជីវវិទូខ្មែរមួយរូបដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញលើឆាកអន្តរជាតិគឺលោក សំ វាសនា។ ដោយមានការឧបត្ថម្ភគាំទ្រពីសួនសត្វអាល់វិតធឿស្សូម៉ឹនស្ទឿ (Allwetterzoo Munster) និងសួនសត្វហ្សេតជីអេភី ZGAP (Zoological Society for the Conservation of Species and Populations) នៅប្រទេសអាល្លឺម៉ង់ ទើបមជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះអាចចាប់ផ្តើមដំណើរការណ៍មជ្ឈមណ្ឌលរបស់ខ្លួនបាន ចាប់តាំងពីឆ្នាំ២០០៣ មក។

# ហេតុអ្វីបានជា ACCB សង្គ្រោះសត្វព្រៃ

សត្វមួយចំនួនដែលត្រូវបានជួយសង្គ្រោះ ហើយបានរក្សាទុកនៅក្នុង ACCB ក្រោមហេតុផលសំខាន់ៗបី (៣) យ៉ាងគឺ៖

**១. ដើម្បីស្តារនីតិសម្បទាមុនពេលលែង៖**

មុននឹងអាចលែងសត្វទាំងនោះបានក្នុងពេលវេលាសមស្របណាមួយ ពួកវាទាំងនោះត្រូវបានពិនិត្យពិច័យយ៉ាងល្អិតល្អន់ ឱ្យប្រាកដថាពួកវាមានសុខភាពល្អហើយពួកវាទទួលបានការព្យាបាលត្រឹមត្រូវដោយពេទ្យសត្វ (ប្រសិនបើចាំបាច់) ហើយរក្សាទុកពួកវានៅក្នុងទ្រុងធំល្មម ដែលជាកន្លែងពួកវាអាចអនុវត្តការស្វែងរកចំណីដោយខ្លួនឯងនិងការឡើងដើមឈើ ឬ ហើរបាន។ វាក៏ជារឿងដ៏សំខាន់ផងដែរ ដែលពួកវារៀនស្គាល់និងចេះគេចខ្លួនផុតពីការគំរាមកំហែងទាំងឡាយ ជាពិសេសពីពពួកសត្វរំពានិងមនុស្សជាដើម។

# ហេតុអ្វីបានជា ACCB សង្គ្រោះសត្វព្រៃ

## ២. សត្វព្រៃដែលសង្គ្រោះបានហើយ តែមិនអាចលែងបានៈ

ក្នុងករណីខ្លះសត្វបានមកដល់ ACCB ដោយមានរបួសធ្ងន់ធ្ងរ ដែលមិនអាចព្យាបាលជាសះស្បើយទាំងស្រុងបាន។ **ឧទាហរណ៍ៈ** ករណីបក្សីដែលត្រូវបានបាក់ឆ្អឹងស្លាបធ្ងន់ធ្ងរ ដែលប្រហែលជាមិនអាចហើរបានល្អ ដើម្បីអាចរស់រានមានជីវិតនៅក្នុងព្រៃឡើយ។ **ឧទាហរណ៍ៈ** សត្វសាំង (សត្វមិនខ្លាចមនុស្ស) សត្វសាំងមិនអាចលែងបានទេពីព្រោះពួកវានឹងត្រូវគេបរបាញ់ ឬ ចាប់ម្តងទៀត។ ពួកសត្វទាំងអស់នេះត្រូវបានដាក់ឱ្យរស់នៅក្នុងជម្រកអចិន្ត្រៃយ៍នៅក្នុង ACCB។

## ៣. ប្រភេទសត្វព្រៃដែលចាំបាច់ត្រូវតែអភិរក្សៈ

សត្វកម្រនិងកំពុងរងគ្រោះជិតផុតពូជបំផុត មួយចំនួនត្រូវបានរក្សាទុកនៅ ACCB ដើម្បីជៀសវាងពីការវិនាសផុតពូជនៅក្នុងព្រៃ។ ពួកវាអាចបន្តពូជបានជារៀងរាល់ឆ្នាំ ប៉ុន្តែ ACCB ធ្វើយ៉ាងណាឱ្យប្រាកដថាសត្វទាំងនោះនឹងមិនបានបាត់បង់សមត្ថភាពក្នុងការរស់រានមានជីវិតនៅក្នុងព្រៃរបស់ពួកវាឡើយ។ ពួកយើងសង្ឃឹមថានាពេលអនាគត ការការពារទីជម្រកធម្មជាតិរបស់ពួកវានឹងមានភាពប្រសើរឡើង បន្ទាប់មក ACCB អាចនឹងលែងពួកវាឱ្យត្រឡប់ទៅរស់នៅក្នុងជម្រកធម្មជាតិរបស់វាវិញ។

# ផ្នែកទី ១៖ ការរក្សាទុកសត្វព្រៃនៅតាមផ្ទះ គឺជាអំពើខុសនឹងច្បាប់

យោងទៅតាមច្បាប់នៃប្រទេសកម្ពុជាដែលបានចែងយ៉ាងច្បាស់ថា យើងត្រូវការពារសត្វព្រៃទាំងអស់ ហើយរាល់សកម្មភាពបរបាញ់សត្វ ការដាក់អន្ទាក់សត្វ ការប្រមាញ់សត្វ ការជួញដូរនិងការចិញ្ចឹមសត្វព្រៃ គឺជាអំពើខុសច្បាប់គ្រប់ករណីទាំងអស់។

**ច្បាប់ស្តីពីព្រៃឈើនៅប្រទេសកម្ពុជា (ឆ្នាំ ២០០២) បានចែងយ៉ាងច្បាស់ថា៖**

- **មាត្រា ៤៩:** ហាមឃាត់ដាច់ខាតរាល់ការបរបាញ់សត្វ ការឃាយី ឬ ការរំខានដល់សត្វព្រៃគ្រប់ប្រភេទ ដោយប្រើប្រាស់ឧបករណ៍គ្រោះថ្នាក់គ្រប់ប្រភេទ ការបរបាញ់សត្វក្នុងរដូវកាលហាមឃាត់និងនៅក្នុងតំបន់អភិរក្ស។ ចំពោះប្រភេទសត្វកម្រនិងកំពុងរងគ្រោះជិតផុតពូជបំផុត ជាទូទៅត្រូវបានហាមឃាត់រាល់សកម្មភាពទាំងអស់ដូចជា ការបរបាញ់ ការឃាយី ការដាក់អន្ទាក់ ការដាក់អង្គប់ ការបំពុល ការដឹកជញ្ជូន ការជួញដូរ ការនាំចេញនិងនាំចូល ព្រមទាំងការចិញ្ចឹមសត្វទាំងនោះក្នុងសួនសត្វ ឬ នៅតាមផ្ទះ។
- **មាត្រា ៥០:** ចំពោះប្រភេទសត្វសាមញ្ញ មួយចំនួនអាចអនុញ្ញាតឱ្យចិញ្ចឹមក្នុងសួនសត្វ ឬ តាមផ្ទះបាន។ ប៉ុន្តែរាល់ការនាំចេញនិងនាំចូលប្រភេទសត្វទាំងនោះ អាចធ្វើទៅបានលុះត្រាតែមានលិខិតអនុញ្ញាតចេញដោយរដ្ឋបាលព្រៃឈើជាមុនសិន។

# ផ្នែកទី ២៖ សុវត្ថិភាពជាចំបង!

**សុវត្ថិភាពរបស់អ្នកជាចំបង!**

- ពួកសត្វមានពិសមួយចំនួន៖ ពស់ រញ៉េ..........
- ជំងឺឆ្លងហួរណូស ZOONOSES៖ ជំងឺឆ្លងរវាងមនុស្សនិងសត្វ
- ការរងរបួសដែលបង្កដោយសត្វព្រៃ

ប្រសិនបើអ្នកមិនប្រាកដថា អ្នកអាចនឹងចាប់ កាន់សត្វនិងដឹកជញ្ជូនសត្វប្រកបដោយសុវត្ថិភាព ដោយមិនបង្កគ្រោះថ្នាក់ដល់ខ្លួនអ្នកផ្ទាល់និងសត្វនោះទេ សូមកុំធ្វើរឿងនេះអី!

# ពួកសត្វមានពិសៈ ពស់

- **វិធានសំខាន់បំផុតៈ** សូមកុំចាប់ ឬ កាន់សត្វពស់ ប្រសិនបើអ្នកមិនអាចកំណត់អត្តសញ្ញាណរបស់វាបានច្បាស់លាស់ថា តើវាជាប្រភេទសត្វពស់ដែលមានពិស ឬ គ្មានពិសនោះទេ!
  - ការចាប់ ឬ កាន់សត្វពស់មានពិស តម្រូវឱ្យមានការអនុវត្តច្រើនហើយមិនអាចបង្រៀនក្នុងរយៈពេលខ្លីបាននោះឡើយ





# ពួកសត្វមានពិសៈ ពស់

ពពួកសត្វពស់មានពិសមួយចំនួន ដែលបង្កគ្រោះថ្នាក់ជាញឹកញាប់នៅកម្ពុជា៖

(រូបភាពនៅទំព័រទី៨ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងលើ)

១. ពស់ពញ្ញាក់ Malayan Pit Viper *(Calloselasma rhodostoma)*

២. ពស់ស្រកាចាស់ Eastern Russell's Viper or Siamese Russell's Viper *(Daboia siamensis)*

៣. ពស់ហនុមាន White-lipped pit viper *(Trimeresurus albolabris)*

៤. ពស់ផ្កាថ្មអុចចំហៀងខ្លួន Small-spotted Coral Snake *(Calliophis maculiceps)*

(រូបភាពនៅទំព័រទី៨ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងក្រោម)

៥. ពស់ក្រាយស ខ្មៅ Malayan Krait or Common Krait or Blue Krait *(Bungarus candidus)*

៦. ពស់ក្រាយលឿង ខ្មៅ Banded Krait *(Bungarus fasciatus)*

៧. ពស់វែករនាម King cobra *(Ophiophagus hannah)*

៨. ពស់វែកដំបូក Monocellate Cobra or Monocled Cobra *(Naja kaouthia)*

# ពួកសត្វមានពិសៈ ពស់










# ពួកសត្វមានពិសៈ ពស់

- តើវាជារឿងសមហេតុផលឬទេ ក្នុងការបណ្តេញសត្វពស់ចេញ ឬ សម្លាប់សត្វពស់ដើម្បីឱ្យមនុស្សមានសុវត្ថិភាព?
  - ពស់ភាគច្រើនវាចឹកមនុស្សនៅពេលដែលយើងព្យាយាមចាប់ ឬ ក៏សម្លាប់វា
  - នៅប្រទេសកម្ពុជាយើងមានពស់ប្រហែលជា ៥% ប៉ុណ្ណោះ ដែលមានពិស ហើយអាចបង្កគ្រោះថ្នាក់ដល់មនុស្សបាន
  - ពស់គឺជាប្រភេទសត្វត្រួតត្រាដែនដីរបស់វា ជាធម្មតាបន្ទាប់ពីយើងបណ្តេញពស់មួយនោះចេញ ពស់មួយផ្សេងទៀតនឹងចូលមកត្រួតត្រាដែនដីនោះ ហើយពស់ថ្មីនោះអាចធំជាងមុន ឬ មានគ្រោះថ្នាក់ខ្លាំងជាងមុនទៅទៀត
  - ប្រសិនបើយើងបណ្តេញពស់នោះចេញ (ផ្លាស់ទីលំនៅរបស់វាដោយបង្ខំ) ពស់នោះប្រាកដជាព្យាយាមត្រលប់មកលំនៅរបស់វាវិញ



# ពួកសត្វមានពិស៖ រញ្ជី

- សត្វរញ្ជីមានក្រពេញពិសនៅលើកែងដៃទាំងសងខាងរបស់វា។ ពួកវាអាចលាយពិសជាមួយនឹងទឹកមាត់របស់វា បន្ទាប់មកពួកវាអាចបញ្ជូនពិសដោយការខាំនឹងធ្មេញដ៏មុតស្រួចរបស់វា
- មិនមែនមនុស្សគ្រប់រូបមានប្រតិកម្មចំពោះពិសសត្វរញ្ជីដូចគ្នានោះទេ ជាតិពិសអាចធ្វើការវិវត្តន៍ពីឈឺចាប់ បណ្តាលឱ្យមានដំបៅក្លាយ ហើម ហើយរហូតដល់ស្លាប់ក៏មាន
- ត្រូវប្រើស្រោមដៃក្រាស់ៗ (ស្រោមដៃក្រាស់ៗធ្វើពីស្បែកដែលគេប្រើសម្រាប់ផ្សារដែក) ជាប់ជានិច្ចនៅពេលចាប់សត្វរញ្ជី
    - ត្រូវមានការប្រុងប្រយ័ត្នខ្ពស់បំផុត ព្រោះសត្វរញ្ជីនៅតែអាចខាំទម្លុះស្រោមដៃស្បែកបាន



# ពួកសត្វមានពិសៈ រញ្ជើ





# ជំងឺឆ្លងហ្សូណូស ( ZOONOSES )៖ ជំងឺឆ្លងរវាងមនុស្សនិងសត្វ

- សត្វស្ទើរតែគ្រប់ប្រភេទមានផ្ទុកជំងឺផ្សេងៗគ្នា
  - មិនមែនគ្រប់ជំងឺទាំងអស់ ជាជំងឺឆ្លងហ្សូណូសនោះទេ
  - ប៉ុន្តែស្ទើរគ្រប់ប្រភេទទាំងអស់មានផ្ទុកជំងឺឆ្លងហ្សូណូស
    - ត្រូវប្រុងប្រយ័ត្នជាពិសេសចំពោះ ពពួកសត្វស្វានិងទោច
- ពិតប្រាកដណាស់ មិនមែនគ្រប់សត្វទាំអស់ផ្ទុកជំងឺនោះឡើយ
- ប៉ុន្តែសត្វមានជំងឺពេលខ្លះមើលទៅដូចធម្មតា ( ដូចជាគ្មានជំងឺ )
  - ត្រូវការពារខ្លួនអ្នកជាប់ជានិច្ចគ្រប់ពេលដែលអ្នកចាប់សត្វ



# ឧទាហរណ៍៖ ជំងឺអែប៉េសប្រភេទបេ( HERPES B ) ដែលឆ្លងពីវីរុស មានផ្ទុកក្នុងខ្លួនពួកសត្វស្វា

- សត្វស្វាប្រហែល ៨ក្បាល ក្នុងចំណោម ១០ក្បាល ដែលមានផ្ទុកវីរុសនេះជាអចិន្ត្រៃយ៍ទៅហើយ
  - សត្វស្វាភាគច្រើនមើលទៅមានសភាពដូចធម្មតា ( ដូចគ្មានជំងឺ )
  - ស្វាមួយចំនួនមានដំបៅតូចៗនៅក្នុងក្រអូមមាត់របស់ពួកវា
- វីរុសអែប៉េសប្រភេទបេ អាចចម្លងទៅមនុស្សបាននៅពេលស្វាខាំ ឬ ខ្វាច
- ជំងឺនេះកម្រកើតឡើងចំពោះមនុស្សណាស់ ប៉ុន្តែបើកើតមានហើយអាចនឹងបណ្តាលឱ្យស្លាប់បាន
  - វីរុសអែប៉េសប្រភេទបេ បង្កឱ្យមានជំងឺខួរក្បាល



# ឧទាហរណ៍៖ ជំងឺផ្តាសាយបក្សី



- ជំងឺនេះកើតឡើងចំពោះសត្វមាន់និងទាស្រុក ប៉ុន្តែប្រភេទបក្សីព្រៃក៏អាចឆ្លងនិងចម្លងជំងឺនេះបានដែរ
  - ច្រើនកើតឡើងចំពោះប្រភេទទានិងបក្សីរំពា
  - សូមកុំរក្សាទុកបក្សីព្រៃនៅក្បែរបក្សីស្រុក (មាន់ទា)!
  - កុំយកសាច់មាន់ទាស្រស់ៗ ឬ ស៊ុតរបស់ពួកវា មកធ្វើជាចំណីសត្វព្រៃ!
- ជំងឺនេះអាចឆ្លងទៅមនុស្សបានតាមរយៈខ្យល់
- អាចបង្កឱ្យមានជំងឺរលាកសួតដែលគំរាមកំហែងដល់អាយុជីវិតរបស់មនុស្ស

# ឧទាហរណ៍៖ បរាសិតបក្សី (មេរោគព្រូនល្អិតៗ) ដ៏សាមញ្ញមួយចំនួន

- សត្វស្ទើរតែគ្រប់ប្រភេទទាំងអស់រួមទាំងមនុស្សផង មានផ្ទុកបាក់តេរីជាច្រើនប្រភេទខុសៗគ្នា។
- ប្រសិនបើសត្វនោះមានសុខភាពល្អនិងមានកាយសម្បទាមាំមួន វាអាចផ្ទុកបាក់តេរីនិងបរាសិតទាំនោះបាន ដោយគ្មានជំងឺនោះទេ ប៉ុន្តែវាក៏ត្រូវការរយៈពេលយ៉ាងយូរដើម្បីកសាងភាពស៊ាំនោះបាន។
  - បរាសិតអាចបង្កឱ្យមានបញ្ហាសុខភាពធ្ងន់ធ្ងរចំពោះបក្សី ហើយវាក៏អាចឆ្លងទៅសត្វដទៃទៀតនិងមនុស្សផងដែរ។
  - មិនត្រឹមតែជាដង្កូវព្រូន ឬ សត្វល្អិតប៉ុណ្ណោះទេ បរាសិតមានរូបរាងផ្សេងៗគ្នាយ៉ាងច្រើន (សូមមើលរូបភាព)។
  - ប្រសិនបើយើងឆាប់បានដឹង បរាសិតបក្សីទាំងនោះ អាចព្យាបាលបាន







# ឧទាហរណ៍៖ ជំងឺឆ្កែឆ្កួត

- ជំងឺនេះអាចប៉ះពាល់ដល់ថនិកសត្វគ្រប់ប្រភេទ ប៉ុន្តែភាគច្រើនកើតឡើងចំពោះឆ្កែស្រុក ពពួកមំសាសីថ្នាក់តូច( សត្វភេ សំពោច។ល។) និងពពួកសត្វប្រចៀវនិងជ្រើង
- ជំងឺនេះឆ្លងតាមរយៈការខាំនិងការប៉ះពាល់ផ្ទាល់ជាមួយនឹងទឹកមាត់របស់វា
- ជំងឺឆ្កែឆ្កួតអាចធ្វើឱ្យមនុស្សនិងសត្វស្លាប់ ប៉ុន្តែជំងឺនេះអាចការពារបាន។ មុនពេលចេញរោគសញ្ញា វាជារឿងសំខាន់ត្រូវមានការព្យាបាលត្រឹមត្រូវតាមលក្ខណៈវិជ្ជសាស្ត្រឱ្យបានឆាប់តាមដែលអាចធ្វើទៅបានក្រោយពេលសត្វខាំ។
- មានវ៉ាក់សាំងចាក់ការពារពីជំងឺនេះបាន ប៉ុន្តែត្រូវតែព្យាបាលនៅមន្ទីរពេទ្យឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលសត្វខាំ។



# ឧទាហរណ៍៖ ជំងឺសាល់ម៉ូណេឡា (SALMONELLA) ឆ្លងពីបាក់តេរីផ្ទុកក្នុងខ្លួនពពួកសត្វល្មូន

- សត្វល្មូនទាំងអស់ (ពស់ អណ្តើកនិងអន្សង ត្រកួត) មានផ្ទុកបាក់តេរីម៉្យាងហៅថា សាល់ម៉ូណេឡា SALMONELLA នៅក្នុងពោះវៀនរបស់ពួកវា
  - បាក់តេរី SALMONELLA ជាធម្មតាមិនធ្វើឱ្យពួកវាមានជំងឺទេ
- បាក់តេរី SALMONELLA អាចឆ្លងមកមនុស្ស ប្រសិនបើពួកគេបរិភោគសាច់ពពួកសត្វល្មូន ឬ តាមរយៈអាហារដែលមានផ្ទុកសារជាតុពុល
  - ត្រូវលាងដៃឱ្យបានស្អាតជានិច្ច បន្ទាប់ពីការប៉ះពាល់ជាមួយសត្វល្មូន
- បាក់តេរី SALMONELLA ឆ្លងមកមនុស្សបង្កឱ្យកើតជំងឺរាករូសធ្ងន់ធ្ងរ ឈឺពោះនិងក្អួត ក្នុងករណីខ្លះអាចបណ្តាលឱ្យស្លាប់បាន



# ឧទាហរណ៍៖ ជំងឺដង្កូវព្រូន ទ្រីស៊ីណែឡា (TRICHINELLA)




- ទ្រីស៊ីណែឡា TRICHINELLA ជាប្រភេទប៉ារ៉ាស៊ីតដង្កូវព្រូនម្យ៉ាងមានផ្ទុកក្នុងខ្លួនពពួកសត្វជ្រូក ជ្រូកព្រៃនិងពពួកមំសាសីថ្នាក់តូចមានដូចជា ឆ្មាជាវ សំពោច ខ្លាឃ្មុំ
- ទ្រីស៊ីណែឡា អាចឆ្លងមកមនុស្សបាន ប្រសិនបើពួកគេបរិភោគសាច់សត្វទាំងអស់នោះ
  - សូមកុំបរិភោគសាច់សត្វព្រៃទាំងនោះ
- មេរោគនេះអាចបង្កឱ្យមានការឈឺចាប់លើសាច់ដុំ ហើមមុខ គ្រុនក្ដៅ ហើយជួនកាលរហូតដល់ស្លាប់ក៏មាន ដោយបណ្ដាលមកពី ជំងឺខួរក្បាលនិងជំងឺបេះដូង

# វិធានទូទៅដើម្បីជៀសវាងពីជំងឺឆ្លងហួសហេតុ (ZOONOSES)៖ ជំងឺឆ្លងរវាងមនុស្សនិងសត្វ

- សូមចាប់កាន់សត្វណាដែលអ្នកប្រាកដថា អ្នកអាចចាប់កាន់វាបានប្រកបដោយសុវត្ថិភាពប៉ុណ្ណោះ
- ប្រសិនបើមិនចាំបាច់ទេសូមជៀសវាងការប៉ះពាល់ផ្ទាល់ជាមួយនឹងសត្វព្រៃទាំងនោះ។ **កុំប៉ះពាល់ផ្ទាល់ជាមួយនឹងសត្វព្រៃទាំងនោះ ដើម្បីគ្រាន់តែជាការសប្បាយអី!**
- សូមលាងដៃរបស់អ្នកជាមួយនឹងសាប៊ូជានិច្ច ក្រោយពេលប៉ះពាល់សត្វព្រៃដោយផ្ទាល់
- ជៀសវាងកុំប៉ះពាល់ផ្ទាល់ជាមួយនឹងលាមក ឈាម ទឹកនោម ឬ ទឹកមាត់របស់សត្វៈ ប្រើស្រោមដៃជ័រ (ស្រោមដៃប្រើតែមួយដងបោះចោល)
- **ប្រើម៉ាស់៖** ជាពិសេសពេលចាប់ប្រភេទសត្វស្លាប ឬ ពពួកពានរ
- **ប្រើស្រោមដៃជ័រ៖** ជាពិសេសពេលចាប់ពពួកថនិកសត្វនិងពពួកសត្វល្មូន
- កុំបរិភោគសាច់សត្វព្រៃ ឬ សំណាកសត្វព្រៃផ្សេងៗទៀត
- កុំរក្សាទុកសត្វព្រៃនៅជិតកន្លែងដែលអ្នកបរិភោគអាហារ ឬ រៀបចំអាហារ

# សម្ភារៈចាំបាច់មួយចំនួនដែលអ្នកត្រូវមានក្នុងពេលចាប់កាន់សត្វព្រៃ












# ការរងរបួសដែលបង្កដោយសត្វព្រៃ៖ របួសស្នាមដោយសារសត្វខាំនិងខ្វាច

១. សូមលាងសម្អាតមុខរបួសជាមួយទឹក និងសាប៊ូឱ្យបានស្អាតភ្លាមៗ តាមដែលអាចធ្វើទៅបាន

- ប្រសិនបើមុខរបួសនោះបង្កឡើងដោយថនិកសត្វ។ **ត្រូវលាងសម្អាតមុខរបួសឱ្យបាន១៥នាទី!**

២. ប្រើថ្នាំសម្លាប់មេរោគ លាបលើមុខរបួស ( **ឧទាហរណ៍:** ដូចជាថ្នាំបេតាឌីន BETADINE ជាដើម )

៣. ប្រើបង់រុំរបួស (រុំមុខរបួសដោយផ្សើមជាមួយនឹងថ្នាំសម្លាប់មេរោគ )

**៤. ទៅជួបពិភាក្សាជាមួយគ្រូពេទ្យជាបន្ទាន់ប្រសិនបើ:**

- របួសស្នាមដែលបានបង្កឡើងដោយពពួកថនិកសត្វ(**លោកអ្នកត្រូវចាក់វ៉ាក់សាំងការពារជំងឺឆ្កែឆ្កួតក្នុងអំឡុងពេល ២៤ម៉ោង**)
- របួសស្នាមដែលបានបង្កឡើងដោយពពួកពស់មានពិស
- មុខរបួសដែលធំពេក ឬ ជ្រៅពេក
- មុខរបួសដែលមានការឈឺចាប់ខ្លាំង ហើមខ្លាំង ឬ រីករាលដាលកាន់តែធំឡើងៗ
- អ្នកចាប់ផ្តើមមានអាការមិនស្រួលខ្លួន (ដូចកំពុងមានជំងឺអ្វីមួយ)

# ផ្នែកទី ៣៖ បច្ចេកទេសចាប់កាន់សត្វព្រៃ (ចាប់កុំឱ្យរើខ្លួនរួច) ចំពោះប្រភេទសត្វមួយចំនួនដែលអ្នកតែងតែជួបប្រទះ

ប្រសិនបើអ្នកមិនប្រាកដថា អ្នកអាចចាប់ កាន់សត្វនិងដឹកជញ្ជូនសត្វប្រកបដោយសុវត្ថិភាព ដោយមិនបង្កគ្រោះថ្នាក់ដល់ខ្លួនអ្នកផ្ទាល់និងសត្វនោះទេ សូមកុំធ្វើរឿងនេះអី!

សត្វមួយក្បាលងាយនឹងស្លាប់បាន ដោយសារសភាពតានតឹងផ្លូវចិត្ត (ជំងឺស្ត្រេស)៖ ជានិច្ចជាកាល នៅពេលដែលអ្នកចាប់សត្វ សូមប្រើរយៈពេលឱ្យបានយ៉ាងខ្លីបំផុតតាមដែលអាចធ្វើទៅបាន។

# តើសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) អាចធ្វើឱ្យសត្វស្លាប់បានដោយវិធីណា៖ ជំងឺសាច់ដុំ

- សភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស)→ សីតុណ្ហភាពក្នុងខ្លួនកើនឡើង→ ការកន្ត្រាក់សាច់ដុំដែលបណ្តាលមកពីកំដៅក្នុងខ្លួនឡើងខ្លាំង (ជំងឺសាច់ដុំ) → តំរងនោមអត់ដំណើរការ ឬ បេះដូងឈប់ដើរ → សត្វនឹងស្លាប់
  - សត្វអាចស្លាប់ភ្លាមៗមកពីជំងឺគាំងបេះដូង
  - ឬអាចស្លាប់ពីរបីថ្ងៃបន្ទាប់ពីទទួលរងនូវសភាពតានតឹងផ្លូវចិត្ត(ជំងឺស្រ្តេស)ដោយសារខូចតំរងនោម
- ជំងឺប្រភេទនេះមិនអាចព្យាបាលបានទេ មានតែវិធីជៀសវាងប៉ុណ្ណោះ
- ប្រភេទសត្វដែលងាយនឹងរងផលប៉ះពាល់ជាមួយនឹងជំងឺនេះ៖ **ស្ទើរតែគ្រប់ប្រភេទសត្វទាំងអស់!** ប៉ុន្តែប្រភេទសត្វមួយចំនួនងាយនឹងកើតជំងឺនេះបំផុត មានដូចជា:
  - ពពួកប្រើស រមាំង ឈ្លូស
  - ពពួកសត្វក្រៀល សត្វត្រយង សត្វក្ងោក សត្វបក្សីក្នុងលំដាប់ស្វាំង (បក្សីរំពា)
- **ការបង្ការ៖** ដើម្បីជៀសវាងសភាពតានតឹងផ្លូវចិត្តខ្លាំង (ជំងឺស្រ្តេស) និងកុំឱ្យមានការឡើងកំដៅខ្លាំង
  - ជៀសវាងការដេញបង្អើលសត្វ

# តើសភាពតានតឹងផ្លូវចិត្ត( ជំងឺស្រ្តេស ) អាចធ្វើឱ្យសត្វស្លាប់បានដោយវិធីណាះ ជំងឺសាច់ដុំ

- ពេលចាប់កាន់សត្វ ជានិច្ចកាលត្រូវប្រើពេលវេលាឱ្យបានខ្លីបំផុត តាមដែលអាចធ្វើទៅបាន។ វាជាការប្រសើរ ប្រើពេលឱ្យបានតិចជាង ៥នាទី
  - ត្រូវត្រៀមសម្ភារៈគ្រប់យ៉ាងជាស្រេច មុនពេលចាប់កាន់សត្វ
  - កុំឈប់ឱ្យគេថតរូប ខណៈពេលដែលអ្នកកំពុងចាប់កាន់សត្វ
- ជៀសវាងជំងឺស្រ្តេសរូបី ( VISUAL STRESS ) កុំឱ្យសត្វមើលឃើញបរិស្ថានជុំវិញវាៈ
  - គ្របភ្នែកសត្វឱ្យជិត ខណៈពេលចាប់កាន់វា
  - យកក្រណាត់ភួយ គ្របពីលើទ្រុងដឹកជញ្ជូនសត្វ
- រក្សាទុកសត្វនៅក្នុងកន្លែងត្រជាក់និងក្រោមម្លប់ជានិច្ច
- មិនត្រូវរក្សាទុកទ្រុងដឹកជញ្ជូនសត្វ នៅក្រោមភ្លៀងឡើយ
- មិនត្រូវដឹកជញ្ជូនសត្វ ឬ រក្សាទុកសត្វព្រៃ ដោយចងនឹងខ្សែនោះទេ







# ការចាប់កាន់ពួកសត្វមំសាសីថ្នាក់តូចៈ ភេ សំពោច ឆ្មាដាវ

- ពួកវានឹងព្យាយាមខាំហើយខ្វាច
  - ស្រោមដៃស្បែកអាចជួយបាន ប៉ុន្តែពួកវានៅតែអាចខាំទម្លុះបានដែល
  - សម្ភារជំនួយផ្សេងៗ៖ សំណាញ់នីឡុង ភួយក្រាស់ៗ
- ប្រសិនបើអាច រក្សាសត្វប្រភេទនេះនៅក្នុងប្រអប់ ឬ ទ្រុងដដែលតែម្តងទៅ
- ការផ្ទេរទៅប្រអប់ ឬ ទ្រុងផ្សេងទៀត គួរប្រើវិធីយ៉ាងណាឱ្យពួកវាដើរចូលទ្រុងមួយផ្សេងទៀតដោយខ្លួនឯង
- ចំពោះពួកសត្វមំសាសីថ្នាក់ធំដែលពេញវ័យហើយ (ខ្លាឃ្មុំ ឬ ខ្លារខិន)៖ ការចាប់កាន់ពួកសត្វប្រភេទនេះដោយសុវត្ថិភាពបាន លើកលែងតែគេចាក់ថ្នាំសណ្តំឱ្យពួកវាសន្លប់ជាមុនសិនប៉ុណ្ណោះ



# ការចាប់កាន់ពួកសត្វមំសាសីថ្នាក់តូចៈ គេ សំពោច ឆ្មាដាវ





# ការចាប់កាន់ពួកសត្វប្រមា

- ពួកវានឹងព្យាយាមដើរថយក្រោយហើយចាក់នឹងកាំរបស់វាដើម្បីការពារខ្លួន
  - ពួកវាមិនអាចបាញ់កាំរបស់វាបានទេ (ផ្ទុយពីពាក្យចាស់និយាយ)
  - ប៉ុន្តែកាំដ៏មុតស្រួចរបស់វា ងាយនឹងចាក់ទម្លុះស្បែកដៃរបស់យើង ក្រណាត់ ស្រោមដៃស្បែកនិងស្បែកជើងកវែង
- សត្វប្រមាក៏អាចខាំដែរ
- កាំរបស់វានឹងចាក់ស្រេះជាប់សំណាញ់នីឡុង ឬ ភួយ → ដូច្នេះការប្រើសាច់សំណាញ់ ឬ ភួយ ក៏មិនសូវបានការប៉ុន្មានដែរ
- ផ្ទេរទៅប្រអប់ ឬ ទ្រុងផ្សេងទៀត គួរប្រើវិធីយ៉ាងណាឱ្យពួកវាដើរចូលទ្រុងមួយផ្សេងទៀតដោយខ្លួនឯងដោយប្រើអំបោស ឬ ឈើក្តារ វាប្រសើរជាងការព្យាយាមចាប់កាន់ពួកវាដោយផ្ទាល់ដៃ



# ការចាប់កាន់ពួកសត្វពានរៈ ស្វាព្រាម ស្វាក្ដាមនិងទោច



- ពួកវានឹងព្យាយាមខាំនិងអាចខ្វាច ហើយប្រឹងរើបម្រះគ្រប់ពេល
  - ត្រូវចងចាំថា ពួកសត្វពានរ តែងតែមានផ្ទុកជំងឺឆ្លងហូរហូស (ZOONOSES )
- មានតែពួកកូនពានរតូចៗប៉ុណ្ណោះដែលយើងអាចចាប់កាន់ដោយដៃបានប្រកបដោយសុវត្ថិភាព
- ជានិច្ចជាកាល គួរតែចាត់ទុកថាពួកពានរធំពេញវ័យពិតជាមានគ្រោះថ្នាក់បំផុត!
  - ផ្ទេរទៅប្រអប់ ឬ ទ្រុងផ្សេងទៀត ដោយប្រើវិធីយ៉ាងណាឱ្យពួកវាដើរចូលទ្រុងមួយផ្សេងទៀតដោយខ្លួនឯង ដោយមិនចាំបាច់ប៉ះពួកវាផ្ទាល់នោះទេ
  - ពានរធំពេញវ័យដែលត្រូវបានគេចិញ្ចឹម ហើយស៊ាំងនឹងមនុស្ស វានឹងដើរចូលទ្រុងដោយខ្លួនវាផ្ទាល់។ ជាទូទៅពួកវាមិនសូវកាច ចំពោះមនុស្សដែលវាស្គាល់នោះទេ

# ការចាប់កាន់សត្វចតុប្បាទ៖ ពួកតិណាសីថ្នាក់តូច (រមាំង ប្រើស) និងជ្រូកព្រៃ គោក្របីព្រៃ

- ពួកតិណាសីថ្នាក់ធំ គ្រោះថ្នាក់ណាស់ក្នុងការចាប់វាៈ
  - ស្នែង ស្នែងប្រើស (ស្នែងបែកខ្នែងជាចម្លាម) ចៃ ឬ ភ្លុករបស់ពួកវា អាចបង្កឱ្យយើងមានរបួសបាន
  - ពួកសត្វខ្លះអាចធាក់ ឬ ខាំបានដែរ
  - ពួកតិណាសីថ្នាក់ធំ មានកំលាំងខ្លាំងណាស់
- ប្រសិនបើស្នែងរបស់វាបាក់នឹងបង្កឱ្យមានការហូរឈាមខ្លាំង
  - សូមកុំចាប់ស្នែងរបស់វា
- ជាពិសេសពួកតិណាសីថ្នាក់តូច ព្រោះពួកវាងាយនឹងទទួលរងសម្ពាធពីសភាពតានតឹងផ្លូវចិត្តខ្លាំងណាស់ៈ **សូមប្រយ័ត្ននឹងជំងឺសាច់ដុំផង!**
  - បើមិនបានចាក់ថ្នាំសណ្តំឱ្យសម្លប់នោះទេ សូមកុំដឹកជញ្ជូនពួកវាទាំងជើងជាប់ចំណង!
  - គួរតែបញ្ជូនពួកវាទៅក្នុងទ្រុងដែលសមស្របទើបជាការប្រសើរ



# ការចាប់កាន់សត្វចតុប្បាទ៖ ពួកតិណាសីថ្នាក់តូច
# ( ឈ្លូស ក្តាន់ ក្តាន់ព្រៀងតូច )







# ការចាប់កាន់ពួកសត្វស្លាបៈ វិធានទូទៅ







- សូមកុំចាប់ ឬ កាន់ស្លាប ឬ ជើងរបស់សត្វស្លាប
  - ឆ្អឹងរបស់ពួកវាផុយស្រួយហើយងាយនឹងបាក់បែកខ្លាំងណាស់

# ការចាប់កាន់ពួកសត្វស្លាបៈ វិធានទូទៅ

- ចាប់ដងខ្លួនផ្នែកខាងលើរបស់សត្វស្លាប ជាការល្អ ត្រូវក្តោបស្លាបរបស់វាឱ្យជិត
- ប្រើក្រណាត់មានការងាយស្រួលជាង( ដូចជាក្រមា ជាដើម )



# ការចាប់កាន់ពួកសត្វស្លាប៖ វិធានទូទៅ









# ការចាប់កាន់ពួកសត្វស្លាបៈ វិធានទូទៅ

- ត្រូវប្រាកដថា អ្នកបានក្តោបស្លាបរបស់បក្សីឱ្យបានជិត ហើយត្រឹមត្រូវតាមទំរង់ដើមពីធម្មជាតិរបស់វា
- សូកម្រាមដៃមួយនៅចន្លោះជើងទាំងពីររបស់សត្វស្លាប
- កុំពង្រួញហើយបត់ជើងរបស់សត្វស្លាបនៅក្រោមដងខ្លួនរបស់វាអី ត្រូវពន្លាតជើងរបស់វាឱ្យអស់
- គ្របភ្នែកទាំងពីររបស់បក្សីឱ្យជិត








# ការចាប់កាន់ពួកសត្វស្លាប៖ វិធានទូទៅ





# ការចាប់កាន់ពួកសត្វពស់

- សង្កត់ក្បាលពស់ផ្អឹបនឹងដីឱ្យជាប់( ឧទាហរណ៍ៈ ជាមួយនឹងអំបោស ) រួចហើយ អាចចាប់ក្បាលពស់ផ្នែកខាងក្រោយ ( កញ្ចឹងក )
  - កុំប្រើមែកឈើស្រួចៗសង្កត់ក្បាលពស់
  - មិនត្រូវប្រើខ្សែអន្ទាក់រូត ក្នុងពេលចាប់ពស់នោះទេ!
- ចាប់ក្បាលពស់ ផ្នែកខាងក្រោយ
  - ជានិច្ចជាកាល ក្នុងពេលចាប់ពស់សូមកាន់ខ្លួនរបស់វាផង ដើម្បីជៀសវាង កុំឱ្យមានរបួសត្រង់ករបស់វា
  - **ឧទាហរណ៍ៈ** មនុស្សម្នាក់កាន់ក្បាលពស់ អ្នកផ្សេងៗទៀតកាន់ដងខ្លួនរបស់វា ក្នុងរវាងប្រវែង ១ម៉ែត្រ ម្នាក់ៗ



# ការចាប់កាន់ពួកសត្វពស់





# ការចាប់កាន់ពួកសត្វអន្សង ត្រកួតនិងក្រពើតូចៗ

- ពួកវា អាចខាំនិងខ្វាច
- **ចាប់វាដោយដៃទាំងពីរ:** ដៃម្ខាងចាប់ក្បាលផ្នែកខាងក្រោយ ដៃម្ខាងទៀតចាប់សង្កត់ត្រង់ត្រគាកនិងពីលើជើងក្រោយទាំងពីររបស់វា (ត្រង់ចំណុចគល់កន្ទុយ)
- ជៀសវាងកុំប្រើខ្សែចងជើងរបស់វា: វាអាចបណ្តាលឱ្យមានជំងឺដំបៅម្រាមជើងបាន
- ចំពោះតែក្រពើប៉ុណ្ណោះ៖ ត្រូវប្រើស្កុតរុំមាត់របស់វាឱ្យជិតកុំឲ្យហារបាន
  - កុំរុំឱ្យជិតរន្ធច្រមុះ ដើម្បីឱ្យសត្វអាចដកដង្ហើមបាន
  - កុំប្រើស្កុតរុំមាត់ចំពោះសត្វផ្សេងៗទៀតឲ្យសោះ





# សត្វជាប់អន្ទាក់

- **សុវត្ថិភាពរបស់អ្នកជាចំបង!៖** ប្រសិនបើអ្នកមិនប្រាកដថា អ្នកអាចនឹងចូលទៅជិតសត្វបានដោយមិនបង្កគ្រោះថ្នាក់ដល់ខ្លួនអ្នកផ្ទាល់នោះទេ **សូមកុំធ្វើរឿងនេះអី!**
  - ទោះបីជាសត្វជាប់អន្ទាក់មិនអាចតតាំងជាមួយនឹងយើងបានក៏ពិតមែន។ តែជាធម្មតា ដោយសារពួកវាមានការភ័យខ្លាចនិងឈឺចាប់ខ្លាំង ដូច្នេះហើយពួកវាក៏អាចវាយប្រហារមកលើយើងហើយបង្កគ្រោះថ្នាក់បានដែរ
  - ចំពោះពួកមំសាសីនិងសត្វចតុប្បាទថ្នាក់ធំ គួរតែទំនាក់ទំនងរកជំនួយពីមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ពួកគេអាចចាក់ថ្នាំសណ្តំឱ្យសត្វសម្លប់សិន ទើបយើងអាចដោះអន្ទាក់បានដោយសុវត្ថិភាព



# សត្វជាប់អន្ទាក់

- ស្នាមជាប់អន្ទាក់៖ សត្វជាប់អន្ទាក់តែងតែមានរបួសហើយចាំបាច់ត្រូវការជំនួយពីពេទ្យសត្វ ដើម្បីធ្វើការពិនិត្យពិច័យនិងព្យាបាលពួកវា
- របួសបង្កឡើងដោយអន្ទាក់ ប្រហែលជាមើលមិនឃើញច្បាស់ ឬ មិនលេចចេញជារូបរាងមកខាងក្រៅទេ ប៉ុន្តែជាធម្មតាកន្លែងដែលរងរបួសនឹងចាប់ផ្តើមដាច់ ឬ បាក់ រយៈពេលពីរ ឬ បី ថ្ងៃបន្ទាប់ (របួសបែកខ្ទាំក្នុងសាច់) ហើយផ្ទៃរបួសទាំងមូលនឹងក្លាយជាដំបៅធំ ដែលដាច់កាន់តែជ្រៅ



# ផ្នែកទី ៤៖ ការផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ

- ទ្រុងដែលសមស្រប សម្រាប់ផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ
- ជៀសវាងសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) និងហានិភ័យផ្សេងៗ
- ការផ្តល់ចំណីអាហារនិងទឹកដល់សត្វព្រៃ

អត្ថបទខាងក្រោមពណ៌នាដោយសង្ខេបអំពី វិធីដឹកជញ្ជូននិងការរក្សាទុកសត្វព្រៃជាបណ្តោះអាសន្ន ក្នុងរយៈពេលខ្លី ពីរ បី ថ្ងៃ (នៅក្នុងស្ថានភាពចាំបាច់ណាមួយ) មុននឹងសត្វទាំងនោះអាចបញ្ជូនទៅកាន់មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬ លែងពួកវាទៅក្នុងព្រៃធម្មជាតិវិញ។

# ទ្រុងដែលសមស្រប សម្រាប់ផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ

**តម្រូវការទូទៅសម្រាប់សត្វស្ទើរតែគ្រប់ប្រភេទទាំងអស់:**

- ទ្រុងដែលមានទំហំធំល្មម (សត្វអាចក្រោកឈរ ផ្តេកខ្លួននិងបង្វិលខ្លួនបាន)
- ទ្រុងមានប្រហោងខ្យល់គ្រប់គ្រាន់
- កុំឱ្យងងឹតឈឹងពេក ប៉ុន្តែជាការល្អត្រូវគ្របនៅតាមជ្រុងនីមួយៗនៃទ្រុង
- ក្រាលក្ដួយជាកម្រាលបាតក្រោម ហើយដាក់បន្ទះឈើ ឬ មែកឈើ ដើម្បីជៀសវាងកុំឱ្យរអិល
- ប្រសិនជាអាចធ្វើបាន សូមរក្សាទុកសត្វក្នុងទ្រុងដាច់ដោយឡែកពីគ្នា (លើកលែងតែសត្វតូចៗដូចជា អណ្ដើកព្រិចនិងកូនសត្វតូចៗ)



# ទ្រុងដែលសមស្រប សម្រាប់ផ្តល់ជម្រកបណ្ដោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ












# ធុងដែលសមស្រប សម្រាប់ផ្តល់ជម្រកបណ្តោះអាសន្ននិងការដឹកជញ្ជូនសត្វព្រៃ

## សម្រាប់ពួកសត្វពស់និងពួកសត្វអន្សង ត្រកួត៖

- ប្រើការ៉ុងអង្ករបិទជិត ២( សម្រាប់ការរក្សាទុកជាបណ្តោះអាសន្នរយៈពេល ២ថ្ងៃ )

## សម្រាប់អណ្តើកទឹកនិងអណ្តើកគោក៖

- ប្រអប់ស្នោ ( ប្រអប់ស្តូឡុង ) ឬ ប្រអប់ជ័រ ( ប្រអប់ផ្លាស្ទិក )
- ត្រូវរក្សាទុកអណ្តើកទឹកនៅក្នុងទឹក
- សម្រាប់ការដឹកជញ្ជូន៖ ដាក់ពួកវានៅលើក្រណាត់សើមៗ





# ជៀសវាងសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) និងហានិភ័យផ្សេងៗ



# ជៀសវាងសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) និងហានិភ័យផ្សេងៗ

**អ្វីដែលគួរធ្វើ៖**

- រក្សាទុកប្រអប់ដែលមានផ្ទុកសត្វព្រៃ នៅកន្លែងដែលម្លប់
- គ្របប្រអប់ផ្ទុកសត្វព្រៃដោយក្អួយស្តើងៗ ឬ ដោយក្រណាត់
- សូមទុកលទ្ធភាពឱ្យសត្វព្រៃបានស្ងប់អារម្មណ៍ផង!

**អ្វីដែលគួរជៀសវាង៖**

- កុំឱ្យសត្វព្រៃជួបប្រទះជាមួយនឹងសត្វដទៃផ្សេងទៀត (ជាពិសេសសត្វស្រុក)
- ជៀសវាងសំលេងរំខាននិងតូរ្យតន្ត្រីខ្លាំងៗ
- ជៀសវាងមនុស្សកុះករពេកនៅជុំវិញពួកវា
- ជៀសវាងផ្សែងភ្លើង
- ជៀសវាងកុំឱ្យមានស្រមោចចូលក្នុងទ្រុងផ្ទុកសត្វព្រៃ

# ជៀសវាងសភាពតានតឹងផ្លូវចិត្ត (ជំងឺស្ត្រេស) និងហានិភ័យផ្សេងៗ





# ការផ្តល់ចំណីអាហារនិងទឹក ដល់សត្វព្រៃ

**តើគប្បីផ្តល់ចំណីអាហារនិងទឹក ដែរឬទេ ?**

ត្រូវតែមានចានទឹកមួយនៅក្នុងទ្រុងសត្វជាប់ជានិច្ចៈ

- **សត្វអណ្តើកទឹកៈ** ត្រូវដាក់ទឹកគ្រប់គ្រាន់ដែលអណ្តើកអាចហែលលេងបាន

ត្រូវផ្តល់ចានចំណីដល់ ពួកថនិកសត្វនិងពួកសត្វស្លាបៈ

- **ពួកសត្វល្មូន** អាចរក្សាទុកដោយគ្មានចំណីរយៈពេលពីរ ឬ បីថ្ងៃ ក្នុងករណីចាំបាច់
- **ពួកសត្វស្លាបតូចៗនិងកូនពួកថនិកសត្វ** អាចស្រេកឃ្លានខ្លាំងប្រសិនបើគ្មានចំណី ក្នុងរយៈពេលត្រឹមតែពីរ ឬ បីម៉ោងប៉ុណ្ណោះ

**មិនត្រូវព្យាយាម បញ្ច្រកចំណីសត្វដោយបង្ខំឡើយ!**





# ផ្នែកទី ៥៖ អ្វីដែលត្រូវធ្វើក្រោយពេលទទួលបានសត្វព្រៃ ឬ បន្ទាប់ពីបានជួយសង្គ្រោះសត្វព្រៃរួចហើយ

អ្នកបានទៅទទួលយកសត្វព្រៃមួយក្បាល

លែងចូលក្នុងព្រៃធម្មជាតិវិញភ្លាមៗ

យកទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ (ACCB / ភ្នំតាម៉ៅ) ?

អាចលែងបាន បន្ទាប់ពីការស្តារនីតិសម្បទា

មិនអាចលែងបាន ត្រូវរក្សាទុកនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ

**តើធ្វើដូចម្តេចដើម្បីធ្វើការសម្រេចចិត្តថា តើជម្រើសណាមួយដែលល្អបំផុតក្នុងករណីនីមួយៗ (លែងភ្លាមៗ ឬយកទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ) ?**

# សំណួរទី ១៖ តើសត្វប្រភេទនោះមានដើមកំណើតនៅប្រទេសកម្ពុជា ឬ មិនមែនទេ?

តើសត្វប្រភេទនោះមានដើមកំណើតនៅប្រទេសកម្ពុជា ឬ មិនមែនទេ?

- មិនមែនទេ → កុំលែងវា
- មែន → សូមបន្តទៅសំណួរបន្ទាប់ទៀត

# តើមានបញ្ហាអ្វីកើតឡើងប្រសិនបើយើងលែងប្រភេទសត្វ ដែលមិនមានដើមកំណើតនៅប្រទេសកម្ពុជា

- ពួកវាប្រហែលជា មិនអាចបន្សាំខ្លួនបានជាមួយស្ថានភាពបរិស្ថានក្នុងតំបន់និងប្រភពចំណីអាហារផ្សេងៗ ហើយអាចនឹងស្លាប់ភ្លាមៗបន្ទាប់ពីលែង

**ឬមួយក៏...............**

- ពួកវាប្រហែលជាអាចបន្សាំខ្លួនបាន ហើយក្លាយជាប្រភេទសត្វរាតត្បាត
  - ប្រភេទសត្វរាតត្បាតអាចបណ្តាលឱ្យចំនួនប្រភេទសត្វក្នុងតំបន់មានការថយចុះ ឬ រងគ្រោះដល់ផុតពូជដោយសារពួកវាបំពានលើដែនជម្រកនិងដណ្តើមកន្លែងពងកូន ឬ ប្រភពចំណីអាហារផ្សេងៗរបស់ប្រភេទសត្វក្នុងតំបន់
  - ប្រភេទសត្វរាតត្បាតមានផ្ទុកជំងឺលាក់មុខមួយចំនួន (HIDDEN DISEASES) ដែលអាចចម្លងនិងសម្លាប់ប្រភេទសត្វក្នុងតំបន់ ដែលមានដើមកំណើតនៅប្រទេសកម្ពុជា

# ជំងឺរាតត្បាតមួយប្រភេទ៖ ឧទាហរណ៍ជំងឺផ្សិតទ្រីឌីអូមីកូស៊ីស (CHYTRID FUNGUS)

- ជាជំងឺផ្សិតម៉្យាងដែលរាតត្បាតទូទាំងសកលលោក វាបង្កឱ្យកើតជាជំងឺដំបៅស្បែក(amphibian plague) ហើយបានសម្លាប់សន្តានកង្កែបនិងពួកថលជលិកជាច្រើនប្រភេទផ្សេងទៀត។
- ជំងឺនេះមានដើមកំណើតនៅទ្វីបអាស៊ី ហើយបានរាតត្បាតស្ទើរពាសពេញពិភពលោក នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ *



*S.J. O'Hanlon et al., "Recent Asian origin of chytrid fungi causing global amphibian declines," Science, 360:621–27, 2018.

# ជំងឺរាតត្បាតមួយប្រភេទ៖ ឧទាហរណ៍ជំងឺផ្សិតទ្រីឌីអូមីកូស៊ីស ( CHYTRID FUNGUS )

- ពួកថលជលិកក្នុងតំបន់ អាស៊ីខាងកើតនិងអាស៊ីអាគ្នេយ៍ មិនទាន់មានការរីករាលដាលជំងឺផ្សិតនេះទេ ប៉ុន្តែចំនួនពួកថលជលិកក្នុងទ្វីបអាស៊ីទាំងមូលកំពុងតែមានការថយចុះ។
- ជំងឺនេះជាដើមហេតុបណ្តាលឱ្យមានការថយចុះចំនួនពួកថលជលិកជាច្រើនប្រភេទលើសកលលោក លើសពីនេះទៅទៀតមានថលជលិកពីរ បី ប្រភេទដែលបានផុតពូជទៅហើយ។
- យើងមិនទាន់ដឹងច្បាស់លាស់ពីមូលហេតុដែលបណ្តាលឱ្យមានការថយចុះចំនួនថលជលិកជាច្រើនប្រភេទក្នុងទ្វីបអាស៊ីនៅឡើយទេ។



# ប្រភេទរាតត្បាតមួយចំនួនដែលបានមកដល់ប្រទេសកម្ពុជា ហើយបានបង្កបញ្ហាជាច្រើនរួចទៅហើយ

(រូបភាពនៅទំព័រទី៥៦ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងលើ)

១. កំប្លោក Water hyacinth ( Eichhornia crassipes )

២. បន្លាយូន Giant sensitive plant ( Mimosa pigra )

៣. Red Swamp Crayfish ( Procambarus clarkii )

(រូបភាពនៅទំព័រទី៥៦ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងក្រោម)

៤. ខ្យងយូន Golden-apple-snail មានពីរប្រភេទ ( Pomacea canaliculata and Pomacea maculate )

៥. អណ្តើកត្រចៀកក្រហម ( Red-eared slider -Trachemys scripta elegans )

៦. ត្រីទីឡាព្យា Nile tilapia ( Orechromis niloticus )

# ប្រភេទរាតត្បាតមួយចំនួនដែលបានមកដល់ប្រទេសកម្ពុជា ហើយបានបង្កបញ្ហាជាច្រើនរួចទៅហើយ








# តើប្រភេទសត្វរាតត្បាតសំខាន់ៗណាខ្លះ ដែលអ្នកឧស្សាហ៍ជួបប្រទះ

(រូបភាពនៅទំព័រទី៥៨ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងលើ)

១. បង្កួយយក្ស Iguanas (Green Iguanas- *Iguana iguana*) មានដើមកំណើតនៅអាមេរិកខាងត្បូង

២. សេកក្រវាត់ក (Ring-necked parakeets- *Psittacula krameri*) មានដើមកំណើតនៅទ្វីបអាហ្វ្រិក និងឥណ្ឌា

៣. ទន្សាយស្រុក (Domestic rabbit- *Oryctolagus cuniculus*) មានដើមកំណើតនៅអឺរ៉ុប

៤. Common Yabby (Cherax destructor) មានដើមកំណើតនៅអូស្រ្តាលី

(រូបភាពនៅទំព័រទី៥៨ លេខរៀងពីឆ្វេងទៅស្តាំ ជួរខាងក្រោម)

៥. កង្កែបអាមេរិក American bullfrog (Lithobates catesbeianus) មានដើមកំណើតនៅភាគឦសាននៃទ្វីបអាមេរិក

៦. Guppy (Poecilia reticulata) មានដើមកំណើតនៅភាគឦសាននៃអាមេរិកខាងត្បូង

៧. Mosquitofish (Gambusia sp.) មានដើមកំណើតនៅអាមេរិក

៨. ដូងអាហ្វ្រិក African Oil Palm (Elaeis guineensis) មានដើមកំណើតនៅទ្វីបអាហ្វ្រិក

**ទាំងនេះគ្រាន់តែជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ គ្រប់ប្រភេទដែលមិនមានដើមកំណើតនៅកម្ពុជាទាំងអស់អាចក្លាយទៅជាប្រភេទរាតត្បាតបាន!**

# តើប្រភេទសត្វរាតត្បាតសំខាន់ៗណាខ្លះ ដែលអ្នកឧស្សាហ៍ជួបប្រទះ










# ប្រភេទរាត្បាត៖ ឧទាហរណ៍ពួកសត្វសេក ALEXANDRINE PARAKEET (PSITTACULA EUPATRIA)

- មានប្រភេទរង (SUBSPECIES) ដល់ទៅ ៥ប្រភេទ
- មានតែ SIAMESE ALEXANDRINE PARAKEET (*Psittacula eupatria siamensis*) តែមួយគត់ ដែលមានដើមកំណើតនៅប្រទេសកម្ពុជាយើង
- សេកចិញ្ចឹមបង្កាត់ពូជមកពីប្រទេសថៃ ភាគច្រើនជាប្រភេទរងផ្សេងទៀត
  - ប្រសិនបើយើងលែងប្រភេទសត្វរាតត្បាតទាំងនោះ ពួកវានឹងអាចបង្កាត់ពូជជាមួយប្រភេទសត្វក្នុងតំបន់ ឬ ក៏ដន្ទើមដែនជម្រករបស់ពួកវា







# សំណួរទី ២៖ តើសត្វនោះត្រូវបានគេចិញ្ចឹមអស់រយៈពេលយូរប៉ុនណាហើយ ?

តើសត្វនោះត្រូវបានគេចិញ្ចឹម
អស់រយៈពេលយូរប៉ុនណា
ហើយ ?

រយៈពេលយូរ
(វាបានក្លាយជាសត្វចិញ្ចឹម)

យកទៅឱ្យមជ្ឈមណ្ឌល
សង្គ្រោះសត្វព្រៃ

រយៈពេលខ្លី
(ទើបចាប់បានថ្មីៗ)

សូមបន្តទៅសំណួរបន្ទាប់ទៀត

# ហេតុអ្វីបានជាសត្វដែលចិញ្ចឹមអស់រយៈពេលយូរមិនអាចលែងភ្លាមៗបាន

- សត្វដែលត្រូវបានគេចិញ្ចឹមអស់រយៈពេលយ៉ាងយូរ ចាំបាច់ត្រូវទទួលនូវការស្តារនីតិសម្បទា មុនពេលលែងៈ
  - ប្រសិនបើពួកវាត្រូវបានគេឱ្យចំណីខុសក្នុងពេលចិញ្ចឹម ពួកវានឹងមិនស្គាល់ប្រភពចំណីអាហារធម្មជាតិទៀតទេ
  - ពួកវាទម្លាប់រស់នៅជាមួយនឹងមនុស្ស (សាំងនឹងមនុស្ស)
  - ប្រសិនបើពួកវាត្រូវបានគេរក្សាទុកក្នុងទ្រុងតូចចង្អៀត ពួកវានឹងបាត់បង់កម្លាំងហើយកាយសម្បទាមិនសូវរឹងមាំប៉ុន្មានទេ
  - ជាធម្មតា សត្វស្លាបដែលជាប់ចំណង ឬ ដាក់ក្នុងទ្រុងតូចៗមានខូចខាតរោមស្លាប

# ហេតុអ្វីបានជាសត្វដែលគេចិញ្ចឹមរស់រយៈពេលយូរមិនអាចលែងវិញបាន





# សំណួរទី ៣៖ តើសត្វនោះនៅក្មេង (កូនសត្វ) ឬ ធំពេញវ័យហើយ?

តើសត្វនោះស្ថិតក្នុងវ័យណា?

- សត្វនៅក្មេង (កូនសត្វ) ឬ មិនប្រាកដទេ? → យកទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ
- សត្វធំពេញវ័យហើយ → សូមបន្តទៅសំណួរបន្ទាប់ទៀត

# ហេតុអ្វីបានជាកូនសត្វជាធម្មតាមិនអាចលែងភ្លាមៗបាន?

- កូនសត្វតូចៗពឹងផ្អែកលើការថែទាំរបស់មេវា ប្រសិនបើអវត្តមានមេរបស់វាចាំបាច់ត្រូវការអ្នកជួយបញ្ចុកចំណី
  - ករណីលើកលែង: ចំពោះពួកសត្វល្មូន
- កូនសត្វតូចៗងាយនឹងភិតភ័យខ្លាំង ហើយពួកវាអាចនឹងស្លាប់បើមិនបានបញ្ចុកចំណីវាក្នុងរយៈពេលពីរ បី ម៉ោង ឬ ប្រសិនបើពួកវារងាខ្លាំងពេក!
  - កុំបង្អង់យូរ ត្រូវប្រញាប់បញ្ជូនពួកវាទៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ!







# ហេតុអ្វីបានជាកូនសត្វជាធម្មតាមិនអាចលែងភ្លាមៗបាន ?





# សំណួរទី ៤៖ តើសត្វនោះមានសុខភាពល្អហើយគ្មានរបួសដែរឬទេ?

តើសត្វនោះមាន សុខភាពល្អ ឬ ទេ?

- វាឈឺ ឬ មានរបួស ឬ មិនប្រាកដទេ → យកទៅឱ្យមជ្ឈមណ្ឌល សង្គ្រោះសត្វព្រៃ
- មានសុខភាពល្អ → សូមបន្តទៅសំណួរបន្ទាប់ទៀត

## សំណួរទី ៤៖ តើសត្វនោះមានសុខភាពល្អហើយគ្មានរបួសដែរឬទេ?

- សូមកុំលែងសត្វ ប្រសិនបើពួកវា:
  - បង្ហាញសញ្ញាជំងឺណាមួយ
  - មានស្នាមរបួសផ្សេងៗ
  - មានការបាក់បែក ឬ ខូចខាតផ្នែកណាមួយនៃកាយសម្បទារបស់វា

  (ធ្មេញ រោមស្លាប ចំពុះ.........)
  - មានសភាពស្គមពេក ឬ ធាត់ពេក
  - សត្វជាប់អន្ទាក់
- តើអាចនឹងមានបញ្ហាអ្វីកើតឡើង ប្រសិនបើយើងលែងសត្វឈឺទាំងនោះ?
  - សត្វឈឺនឹងមិនអាចរស់នៅក្នុងព្រៃបានឡើយ ហើយពួកវានឹងស្លាប់ក្នុងរយៈពេលយ៉ាងខ្លីបន្ទាប់ពីការលែង
  - សត្វឈឺអាចចម្លងជំងឺផ្សេងៗទៅសត្វព្រៃផ្សេងទៀតបាន



# វិធីសម្គាល់សត្វមានជំងឺ

**ជាដំបូង សូមធ្វើការសង្កេតមើលសត្វពីចម្ងាយៈ**

- សត្វមានសុខភាពល្អ ផ្លាងខ្លាំង( ឆាប់ផ្អើល ) មានប្រតិកម្មចំពោះមនុស្សនិងសំឡេងរំខានផ្សេងៗ
  - ជាទូទៅពួកសត្វល្អន មានភាពអកម្មជាងសត្វផ្សេងៗទៀត ហើយមិនសូវផ្លាស់ទីញឹកញាប់ទេ

**សត្វឈឺៈ**

- មិនមានប្រតិកម្មចំពោះបរិស្ថានជុំវិញខ្លួនវា មិនក្រោកឈរនិងមិនព្យាយាមរត់គេចទេ ពេលយើងចូលទៅជិតវា
- បិទភ្នែកជាប់ជានិច្ច
- ការប្រើអវយវៈទាំងអស់របស់វាមើលទៅខុសប្រក្រតី (ដើរឃ្លេរជើងមួយចំហៀង ឬ ធ្លាក់ស្លាបមួយចំហៀង.....)
- ចំពោះសត្វស្លាបៈ មានអាការឡើងរោមប្រាង (បាស់រោម)
- ចំពោះអណ្តើកទឹកៈ ប្រហែលជាអាចអណ្តែត ពេលដែលយើងដាក់ចូលក្នុងទឹក

# វិធីសម្គាល់សត្វមានជំងឺ











# វិធីសម្គាល់សត្វមានជំងឺ

បន្ទាប់មក សូមចូលឱ្យជិតសត្វហើយធ្វើការសង្កេតមើលវាឱ្យបានល្អិតល្អន់ ពិនិត្យរកមើលស្នាមរបួសនិងសញ្ញាជំងឺផ្សេងៗ៖

- **ស្ថានភាពរាងកាយៈ** តើសត្វនោះស្គមពេក ឬមួយ ធាត់ពេក
- **ភ្នែកៈ** ភ្នែករូងជ្រៅ (ភ្នែកខូង) ហៀរទឹកភ្នែក ភ្នែកឡើងក្រហម
- **ច្រមុះ ឬ ចំពុះ៖** មានសារធាតុរាវ ឬ ហូរឈាមចេញពីរន្ធច្រមុះ
- ដំបៅ ឬ មុខរបួសផ្សេងៗ
- ដាច់ដោចរោមខ្លួន ឬ រោមស្លាប
- **អណ្តើកទឹកនិងអណ្តើកគោកៈ** ពុកស្នូក

# វិធីសម្គាល់សត្វមានជំងឺ



# វិធីសម្គាល់សត្វមានជំងឺ







# សត្វឈើ: អណ្ដើកទឹកនិងអណ្ដើកគោក ពុកស្នូក

- បញ្ហាពុកស្នូកតែងតែកើតមាន ប្រសិនបើអណ្ដើកទាំងនោះរក្សាទុកមិនបានល្អ បង្កសភាពតានតឹងផ្លូវចិត្ត (ជំងឺស្ត្រេស) ខ្លាំង
  - ជាពិសេសអណ្ដើកស្រែ ដែលងាយនឹងមានបញ្ហាពុកស្នូកណាស់
- ស្នូករបស់វាត្រូវបានបំផ្លាញដោយបាក់តេរីម៉្យាង យ៉ាងឆាប់រហ័ស
  - ស្នូកពុកធ្ងន់ធ្ងរនឹងបណ្ដាលឱ្យ សត្វអណ្ដើកទឹកនិងអណ្ដើកគោកស្លាប់បាន ប្រសិនបើគ្មានការព្យាបាលនោះទេ
  - ស្នូកពុកអាចព្យាបាលដោយបសុពេទ្យបាន ប៉ុន្តែមានផលពិបាក ហើយវាតែងតែត្រូវការពេលវេលាច្រើនខែ ទើបជាសះស្បើយបាន



# សត្វឈឺ៖ អណ្តើកទឹកនិងអណ្តើកគោក ពុកស្នូក







# សត្វឈឺ: សត្វស្លាបដាច់ដោចរោម

- **ចំពោះសត្វស្លាបៈ** រោមគ្រប់ផ្នែកទាំងអស់ត្រូវមានសភាពល្អឥតខ្ចោះ ហើយវាជាការចាំបាច់ សត្វស្លាបត្រូវតែអាចហើរបាន
  - **រោមស្លាប មានសារៈសំខាន់ចំពោះ៖**
    - **ការហើរៈ** ដើម្បីគេចខ្លួនពីសត្រូវនិងការស្វែងរកចំណី
    - ការពារពីភាពត្រជាក់ ការពារកំដៅនិងការពារទឹកភ្លៀង
  - សត្វស្លាបទាំងឡាយណាដែលត្រូវគេកាត់រោមស្លាប ខ្វះរោមស្លាប ដាច់ដោចរោមស្លាប ឬ រោមស្លាបប្រឡាក់ នឹងមិនអាចរស់រានមានជីវិតក្នុងព្រៃបានឡើយ។

**ដូច្នោះហើយ មិនអាចលែងបានទេ!**





# សត្វឈើៈ សត្វដែលត្រូវបានគេកាត់ធ្មេញ ឬ ចង្កូមចេញ

- ពពួកសត្វសំពោច ឆ្មាដាវ ភេ ស្វា ព្រៀៈ
  - ជួនកាលធ្មេញ ឬ ចង្កូមរបស់វាត្រូវបានគេគាត់ចេញ ដើម្បីការពារកុំឱ្យវាខាំ ក្នុងពេលដែលពួកវាត្រូវបានគេដឹកជញ្ជូន ដើម្បីជួញដូរខុសច្បាប់
  - ការកាត់ធ្មេញ ឬ ចង្កូមបែបនេះ ធ្វើឱ្យសត្វមានការឈឺចាប់ខ្លាំង ហើយវានឹងបង្កឱ្យមានការឆ្លងរាលដាលដល់គល់ធ្មេញដែលនៅសេសសល់
  - **ធ្មេញ ឬ ចង្កូមដែលនៅល្អ (មិនទាន់កាត់ចេញ) ពិតជាមានសារៈសំខាន់ណាស់ចំពោះសត្វៈ**
    - សម្រាប់ការប្រមាញ់និងការស្វែងរកចំណី
    - ការវាយប្រយុទ្ធ ដើម្បីការពារខ្លួន
  - សត្វដែលគេកាត់ធ្មេញមិនអាចលែងបានឡើយ



# សំណួរទី ៥៖ តើសត្វនោះខ្លាចមនុស្សដែរឬទេ ?

តើសត្វនោះខ្លាចមនុស្សដែរឬទេ ?

- មិនខ្លាចមនុស្ស (វាជាសត្វសាំងនឹងមនុស្ស) → យកទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ
- ខ្លាចមនុស្ស → សូមបន្តទៅសំណួរបន្ទាប់ទៀត

# សំណួរទី ៥៖ តើសត្វនោះខ្លាចមនុស្សដែរឬទេ ?

- មានតែសត្វផ្លាង (ធាប់ផ្អើលនឹងមនុស្ស) ប៉ុណ្ណោះ ទើបព្យាយាមរត់គេចពីមនុស្ស ហើយអាចលែងបាន
  - ករណីលើកលែង៖ ពួកសត្វល្មូន តែងតែមិនស៊ាំជាមួយមនុស្សទេ

- តើមានអ្វីអាចនឹងកើតឡើង ប្រសិនបើយើងលែងសត្វដែលសាំង ឬ សត្វដែលធ្លាប់រស់នៅជាមួយមនុស្ស ?
  - ពួកវាខ្វះជំនាញរស់រានមានជីវិតក្នុងព្រៃ ហើយនឹងស្លាប់ក្នុងរយៈពេលយ៉ាងខ្លីបន្ទាប់ពីលែង
  - ប្រសិនបើពួកវាមិនគេចពីមនុស្ស ពួកវានឹងត្រូវគេចាប់ម្តងទៀត ឬ ត្រូវគេសម្លាប់
  - ពួកវាអាចបង្កគ្រោះថ្នាក់ដល់មនុស្ស ឬ បង្កការរំខានផ្សេងៗ

# សំណួរទី ៥៖ តើសត្វនោះខ្លាចមនុស្សដែរឬទេ?







# សំណួរទី ៥៖ តើសត្វនោះខ្លាចមនុស្សដែរឬទេ?





- ពួកសត្វស្វាក្ដាម ស្វាព្រាមនិងទោច ពឹងផ្អែកលើមេរបស់វាទាំងស្រុង ក្នុងការរៀនសូត្រពីជំនាញរស់រានមានជីវិតក្នុងព្រៃ
  - ពួកសត្វពានរដែលត្រូវបានគេចាប់មកពីព្រៃមក ហើយដាក់ឱ្យរស់នៅបែកពីមេរបស់វាតាំងពីតូចៗមក ជាធម្មតាមិនអាចលែងពួកវាបានឡើយ
  - ពួកសត្វពានរពឹងផ្អែកលើមេរបស់វារយៈពេលច្រើនឆ្នាំណាស់ (**ចំពោះពួកសត្វទោចៈ រហូតដល់ទៅ ៨ឆ្នាំ!**)

# ឧទាហរណ៍៖ ការប៉ះទង្គិចគ្នារវាងមនុស្សនិងពួកសត្វស្វា ដែលបានបង្កឡើងដោយពួកសត្វស្វាស៊ាំតាមទម្លាប់របស់មនុស្ស

- ហ្វូងសត្វស្វាដែលរស់នៅក្បែរលំនៅដ្ឋានរបស់មនុស្ស ហើយពួកវាមិនខ្លាចមនុស្ស
  - ក្នុងចំណោមសត្វស្វាទាំងនោះ មួយចំនួនគឺជាអតីតស្វាចិញ្ចឹមដែលត្រូវបានគេលែងដោយខុសបច្ចេកទេស
  - ប្រសិនបើមនុស្សនៅតែបន្តឱ្យចំណីសត្វស្វាព្រៃ ពួកវានឹងអសមត្ថភាពក្នុងការស្វែងរកចំណីដោយខ្លួនឯង
- សត្វស្វាទាំងនោះចូលលួច ម្ហូបអាហារនិងសម្ភារប្រើប្រាស់ផ្សេងៗពីមនុស្ស
- សត្វស្វាទាំងនោះអាចចូលក្នុងផ្ទះ អាហារដ្ឋាននិងហាងលក់ឥវ៉ាន់
- ជួនកាលសត្វស្វាទាំងនោះវាយប្រហារ ព្យាយាមដណ្តើមចំណីអាហារជាមួយមនុស្ស
  - សត្វស្វាទាំងនោះអាចមានផ្ទុកមេរោគដ៏គ្រោះថ្នាក់ ដែលអាចចម្លងមកមនុស្សបានតាមរយៈការខ្វាចនិងខាំ៖ ដូចជាវីរុសអែប៉េសប្រភេទបេ (HERPES B) និងជំងឺឆ្កែឆ្កួត
- សត្វស្វាទាំងនោះអាចបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ដោយសារពួកវាចូលចិត្តរស់នៅជិតដងផ្លូវពេក

## ឧទាហរណ៍៖ ការប៉ះទង្គិចគ្នារវាងមនុស្សនិងពួកសត្វស្វា ដែលបាន បង្កឡើងដោយពួកសត្វស្វាស៊ាំតាមទម្លាប់របស់មនុស្ស








# សំណួរទី ៦៖ តើយើងអាចលែងសត្វនោះភ្លាមៗនៅក្នុងជម្រកសមស្របណាមួយបានដែរឬទេ ?

តើសត្វនោះអាចលែងនៅជម្រកសមស្របណាមួយភ្លាមៗបានទេ ?

- លែងមិនបានទេ → យកទៅឱ្យមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ
- លែងបាន → លែងវាទៅ

## សំណួរទី ៦៖ តើយើងអាចលែងសត្វនោះភ្លាមៗនៅក្នុងជម្រកសមស្របណាមួយបានដែរឬទេ?

- ការលែងសត្វ មិនគួរពន្យារពេលយូរជាងពីរ បី ម៉ោង (ឬពីរ បីថ្ងៃ ក្នុងករណីពួកសត្វពស់)
  - សភាពតានតឹងផ្លូវចិត្ត (ជំងឺស្ត្រេស) និងការពន្យារពេលដោយគ្មានចំណី ឬ ទឹកផឹកគ្រប់គ្រាន់ វានឹងជះឥទ្ធិពលជាអវិជ្ជមានដល់ឱកាសរស់រានមានជីវិតរបស់សត្វ ក្រោយពេលលែងក្នុងព្រៃ
- តើមានកន្លែងលែងសមស្របណាមួយនៅជិតនោះទេ?

# ផ្នែកទី ៦៖ ចំណុចមួយចំនួនដែលត្រូវពិចារណា មុនពេលលែងសត្វត្រឡប់ទៅក្នុងព្រៃធម្មជាតិវិញ

ចំណុចមួយចំនួនដែលត្រូវគិតពិចារណា មុនពេលលែងសត្វណាមួយត្រលប់ទៅក្នុងព្រៃធម្មជាតិវិញ៖

- កន្លែងលែងដែល សមស្របនិងមានសុវត្ថិភាព
- ពេលវេលាប្រចាំថ្ងៃ (ម៉ោងណា ពេលណា ពេលថ្ងៃ ឬ យប់) និងស្ថានភាពអាកាសធាតុ
- ពេលវេលាប្រចាំឆ្នាំ (ខែ ឆ្នាំ ឬ រដូវកាល)

# តើកន្លែងបែបណាជាទីតាំងលែងសត្វដែល សមស្របនិងមានសុវត្ថិភាព?

**កន្លែងលែងសត្វដែលសមស្រប:**

- ប្រភេទសត្វទាំងនោះត្រូវតែលែងទៅក្នុងកន្លែងលែងសត្វណាមួយ ដែលជាជម្រករបស់ពួកវាពីធម្មជាតិមក
- ជាកន្លែងដែលមានប្រភពចំណីអាហារ៖ តើកន្លែងនោះមានចំណីធម្មជាតិគ្រប់គ្រាន់សម្រាប់សត្វបន្ទាប់ពីលែងដែរឬទេ?
  - **ឧទាហរណ៍:** កុំលែងអណ្តើកច្រើនក្បាលក្នុងស្រះទឹកតូចមួយ ពីព្រោះវានឹងមិនមានចំណីអាហារគ្រប់គ្រាន់សម្រាប់ពួកវាទាំងអស់នោះឡើយ
- តើវាជាកន្លែងដែលសមស្របពេញមួយឆ្នាំឬទេ? ប្រសិនបើទីជម្រកនោះមានសភាពប្រែប្រួលតាមរដូវកាល វាមិនមែនជាកន្លែងដែលសមស្របពេញមួយឆ្នាំនោះទេ។ **ឧទាហរណ៍:** ប្រសិនបើប្រភពទឹកត្រូវរីងស្ងួតនៅរដូវប្រាំង វាជាកន្លែងមិនសមស្របសម្រាប់លែងអណ្តើកទឹកឡើយ។

មិនមែនកន្លែងលែងសត្វមួយកន្លែងសមស្របសម្រាប់សត្វគ្រប់ប្រភេទនោះឡើយ: កន្លែងលែងសត្វនីមួយៗត្រូវតែបំពេញឱ្យត្រូវតាមតម្រូវការចាំបាច់ របស់ប្រភេទនីមួយៗដែលយើងនឹងលែងវា

# តើកន្លែងបែបណាជាទីតាំងលែងសត្វដែល សមស្របនិងមានសុវត្ថិភាព?

**កន្លែងលែងសត្វដែលមានសុវត្ថិភាព:**

- មានសុវត្ថិភាពពីការគំរាមកំហែងរបស់មនុស្ស ដើម្បីកាត់បន្ថយកុំឱ្យមានការចាប់សត្វម្តងទៀត ឬ ការបរបាញ់
  - **ត្រូវរក្សាការសម្ងាត់:** កុំឱ្យជនខិលខូច (អ្នកជំនាញបរបាញ់សត្វ) ដឹងពីទីកន្លែងដែលយើងលែងសត្វនោះ
- មិនមានសកម្មភាពកាប់បំផ្លាញទីជម្រករបស់វាបន្តទៀត (**ការកាប់ឈើ**)
- **មានសុវត្ថិភាពពីពួកសត្វស្រុក:**
  - សត្វឆ្កែនិងឆ្មា អាចរំខាននិងប្រមាញ់សត្វព្រៃ
  - សត្វស្រុកទាំងនោះអាចបង្កជាជំងឺដ៏មានគ្រោះថ្នាក់ដល់សត្វព្រៃបាន។ **ឧទាហរណ៍ដូចជា:**
    - ជំងឺផ្តាសាយបក្សីកើតចំពោះ ពួកសត្វមាន់និងទាស្រុក ហើយឆ្លងមកពពួកសត្វព្រៃ
    - ជំងឺអុតក្តាម FMD (ប្រភេទជំងឺរលាកប្រអប់ជើងនិងក្រអូមមាត់) កើតចំពោះពួកសត្វគោនិងក្របីស្រុក ហើយឆ្លងមកពួកសត្វទន្សោងនិងខ្ទីង

# តើកន្លែងបែបណាជាទីតាំងលែងសត្វដែល សមស្របនិងមានសុវត្ថិភាព?



កន្លែងដែលមានសកម្មភាពមនុស្សអ៊ូអរ ផ្លូវខ្វាត់ខ្វែងច្រើន សំបូរសត្វចិញ្ចឹមច្រើននិង កន្លែងគ្រោះថ្នាក់ផ្សេងៗទៀត ជាតំបន់មិនសមស្របដល់ការលែងសត្វឡើយ



បុគ្គលិក ACCB កំពុងលែងសត្វពស់ថ្លាន់ ១ក្បាល ទៅក្នុងទីជម្រកសមស្របមួយ ហើយ ជាទីតាំងដែលមានសុវត្ថិភាព

# ពេលវេលាប្រចាំថ្ងៃ (ម៉ោងណា ពេលណា ពេលថ្ងៃ ឬ យប់) និងស្ថានភាពអាកាសធាតុ

- ពេលវេលាប្រចាំថ្ងៃ:
  - ពួកសត្វទិវាចរ (សត្វរកស៊ីពេលថ្ងៃ) ត្រូវតែលែងនៅពេលព្រឹកព្រលឹម
  - ពួកសត្វរាត្រីចរ(សត្វរកស៊ីពេលយប់) ត្រូវតែលែងនៅពេលព្រលប់





- ស្ថានភាពអាកាសធាតុ:
  - ពួកសត្វមួយចំនួនដែលមានសភាពតានតឹងផ្លូវចិត្តខ្លាំង (ជំងឺស្រេស) ជាការល្អប្រសើរត្រូវដឹកទៅដល់កន្លែងលែងសត្វនិងលែងពួកវា ពេលដែលមិនសូវក្តៅខ្លាំង។ ជៀសវាងការលែងសត្វពេលថ្ងៃក្តៅហែងឬក្រោមកំដៅខ្លាំង
  - ការលែងសត្វក្នុងពេលភ្លៀងខ្លាំង អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់សត្វ ជាពិសេសពួកសត្វស្លាប

# ពេលវេលាប្រចាំឆ្នាំ (ខែណា ឬ រដូវណា?)

- ប្រភេទសត្វដែលរស់នៅក្នុងតំបន់ដីសើម គួរតែលែងនៅរដូវវស្សា
  - ធ្វើបែបនេះដើម្បីធានាថា ពួកវានឹងមានចំណីអាហារគ្រប់គ្រាន់សម្រាប់ចិញ្ចឹមជីវិត
- **ប្រភេទសត្វបន្លាស់ទី:** ប្រភេទសត្វស្លាបមួយចំនួនមិនមានវត្តមាននៅប្រទេសកម្ពុជាពេញមួយឆ្នាំទ្បើយ
  - ពួកវាត្រូវតែលែងចំពេលដែលប្រភេទសត្វទាំងនោះ កំពុងមានវត្តមាននៅប្រទេសកម្ពុជានិងនៅកន្លែងលែងសត្វតាមបែបបទធម្មជាតិរបស់ពួកវា
- ពួកសត្វល្មូនទាំងអស់មិនមែនសុទ្ធតែសកម្មដូចគ្នាពេញមួយឆ្នាំនោះទេ
  - ពួកសត្វល្មូនខ្លះៗ អសកម្មប៉ុន្មានសប្តាហ៍ ពេលដែលចុះត្រជាក់ខ្លាំង វាជាការប្រសើរត្រូវលែងពួកវានៅពេលដែលក្តៅល្មម

# ការលែងសត្វ៖ អ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ

គោលបំណងដ៏សំខាន់បំផុតក្នុងពេលលែងសត្វណាមួយ គឺត្រូវធ្វើយ៉ាងណាដើម្បីកាត់បន្ថយសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស) ឱ្យនៅមានកម្រិតទាបបំផុតតាមដែលអាចធ្វើទៅបាន!

នៅពេលណាដែលទីតាំងលែងសត្វសមស្របណាមួយត្រូវបានជ្រើសរើសរួចហើយ ហើយសត្វនោះក៏បានដឹកជញ្ជូនទៅដល់កន្លែងនោះដោយសុវត្ថិភាពហើយដែរ វាជារឿងសំខាន់បំផុតក្នុងការលែងសត្វនោះតាមរបៀបសមស្របមួយ ដែលអាចផ្តល់លទ្ធភាពគ្រប់គ្រាន់ឱ្យសត្វនោះអាចចាប់ផ្តើមជីវិតថ្មី យ៉ាងល្អបំផុត។





# ការលែងសត្វ៖ អ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ

ដើម្បីលែងសត្វមួយក្បាលប្រកបដោយជោគជ័យ វាមានសារៈសំខាន់ណាស់ក្នុងការៈ

**អ្វីដែលគួរធ្វើ៖**

- ដាក់ទ្រុងដឹកជញ្ជូនផ្ទាល់លើដីហើយទុកឱ្យមនុស្សតែម្នាក់គត់បើកទ្រុង ឬ ប្រអប់ (អ្នកដ៏ទៃផ្សេងទៀតគួរតែឈរនៅខាងក្រោយឱ្យឆ្ងាយ ធ្វើយ៉ាងណាកុំឱ្យសត្វដឹងខ្លួន ឬ មើលឃើញ)
- ឈរពីខាងក្រោយប្រអប់ហើយបើកចំហវាឱ្យអស់
- សូមអត់ធ្មត់និងរក្សាភាពស្ងៀមស្ងាត់ (បន្ទាប់បើកប្រអប់ហើយ)
- ទុកលទ្ធភាពឱ្យសត្វចាកចេញពីប្រអប់ដោយខ្លួនឯងនៅពេលណាដែលវាត្រៀមខ្លួនរួចហើយ។ វាអាចត្រូវការពេលយូរគួរសមដែរ។ **កុំព្យាយាមរុញ ឬ ផ្អៀងប្រអប់អី!**
- មើលពីចម្ងាយរហូតដល់សត្វបានចូលទៅក្នុងទីតាំងដែលមានសុវត្ថិភាព
- ពពួកសត្វស្លាបនឹងទុំលើមែកឈើក្បែរហ្នឹង។ យើងអាចរង់ចាំមើលរហូតដល់វាហើរទៅឆ្ងាយ ប៉ុន្តែត្រូវនៅឱ្យឆ្ងាយពីវាជានិច្ច

# ការលែងសត្វ៖ អ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ



មនុស្សម្នាក់ឯងកំពុងលែងសត្វក្នុងរូបភាពនេះ ជាឧទាហរណ៍ដ៏ល្អ។
**ចំណាំ៖** ដាក់ប្រអប់បែរមុខទៅទីតាំង ឬ ជម្រកដែលមានសុវត្ថិភាព



**សម្គាល់៖** ទុកប្រអប់ចោលតែឯង ហើយមើលពីចម្ងាយរហូតដល់សត្វបានចាកចេញទៅកាន់ទីតាំងដែលមានសុវត្ថិភាព

# ការលែងសត្វ៖ អ្វីដែលគួរធ្វើនិងអ្វីដែលមិនគួរធ្វើ

**អ្វីដែលមិនគួរធ្វើ៖**

- បើគ្មានការចាំបាច់ កុំនាំមនុស្សច្រើនពេកទៅកន្លែងលែងសត្វ
- កុំបញ្ឈប់ដំណើរដឹកជញ្ជូនសត្វដើម្បីថតរូបមុនពេលលែងសត្វ
- កុំឈរជិតនឹងទ្រុង ឬ ប្រអប់ដាក់សត្វខ្លាំងពេក។ ធ្វើដូចនេះវាទំនងជាបណ្ដាលឱ្យសត្វនៅសម្ងំក្នុងទ្រុង ឬ ប្រអប់ទាំងភ័យខ្លាច ហើយវានឹងបង្កើនសភាពតានតឹងផ្លូវចិត្ត (ជំងឺស្រ្តេស)
- កុំដេញបង្អើលសត្វឱ្យចេញពីប្រអប់ដឹកជញ្ជូនដោយបង្ខំ
- កុំអង្រួន ឬ គោះប្រអប់ដើម្បីបង្អើលសត្វឱ្យចេញពីប្រអប់
- កុំនិយាយខ្លាំងៗព្រោះវានឹងធ្វើឱ្យសត្វភ័យ ហើយវានឹងមិនចាកចេញពីប្រអប់ដឹកជញ្ជូនឡើយ
- កុំដាក់សារធាតុផ្សេងៗដូចជាម្សៅកូនង៉ែត នៅលើខ្លួនសត្វ
- កុំសរសេរ ឬ គូសនៅលើ ស្នូកអណ្ដើកទឹកនិងអណ្ដើកគោក



# ឧប្បសម្ព័ន្ធ៖ ឯកសារយោង

Stenkat J. et al. 2019. Wildlife and Environment Protection and Conservation, A guide book for Buddhist monks in Cambodia. Angkor Centre for Conservation of Biodiversity

# ឧបសម្ព័ន្ធ៖ សិទ្ធិលើរូបភាព

គំនូរនៅក្របមុខ និងក្របក្រោយ គូរដោយ © ម៉ារៀ ចាវ៉ា ផារូលីន

រូបភាពស្ទើរតែទាំងអស់រក្សាសិទ្ធិដោយ ACCB លើកលែងតែរូបភាពមួយចំនួនដែលបានបញ្ជាក់ឈ្មោះអ្នកថតរូប ដូចខាងក្រោមនេះ

| | | |
|---|---|---|
| ទំព័រ | ៦ | M. Dainty |
| ទំព័រ | ៨ | មិនដឹងប្រភព |
| ទំព័រ | ៩ | C.M. Parolin |
| ទំព័រ | ១៣ | cdn1.sph.harvard.edu |
| ទំព័រ | ១៤ | មិនដឹងប្រភព |
| ទំព័រ | ១៥ | មិនដឹងប្រភព |
| ទំព័រ | ២៤ | J. Stenkat |
| ទំព័រ | ២៩ | មិនដឹងប្រភព |
| ទំព័រ | ២៩ | កណ្ដាល និងខាងស្ដាំៈ មិនដឹងប្រភព |
| ទំព័រ | ៣៤ | ខាងស្ដាំៈ Right: Klinik für Vögel und Reptilien, Universität Leipzig |
| ទំព័រ | ៣៥ | ខាងស្ដាំៈ មិនដឹងប្រភព |
| ទំព័រ | ៣៦ | មិនដឹងប្រភព |
| ទំព័រ | ៣៩ | Nick Marx/ សម្ព័ន្ធមិត្តសត្វព្រៃ |
| ទំព័រ | ៤០ | យ៉ាន់ ប៊ុនសឿង |
| ទំព័រ | ៥២ | Brian Gratwicke, Smithsonian Conservation Biology Institute. |
| ទំព័រ | ៥៥ | ខាងឆ្វេង និងកណ្ដាល (ជួរខាងលើ)ៈ ជិម សុភាព<br>ស្ដាំ និងជួរខាងក្រោមៈ inaturalist |
| ទំព័រ | ៥៧ | Inaturalist |
| ទំព័រ | ៥៨ | មិនដឹងប្រភព |
| ទំព័រ | ៦១ | មិនដឹងប្រភព |
| ទំព័រ | ៦៨ | ខាងឆ្វេង (ជួរខាងក្រោម) មិនដឹងប្រភព |
| ទំព័រ | ៧១ | មិនដឹងប្រភព |
| ទំព័រ | ៨១ | មិនដឹងប្រភព |
| ទំព័រ | ៩៣ | មិនដឹងប្រភព |

អង្គការ WWF បម្រើការងារនៅជាង ១០០ប្រទេស ដើម្បីការកសាងអនាគតសម្រាប់ការរស់នៅប្រកបដោយភាពសុខដុមរមនារវាងមនុស្សជាមួយនឹង ធម្មជាតិ។ ដោយសារសុខុមាលភាពរបស់មនុស្ស សត្វព្រៃ និងបរិស្ថានធម្មជាតិ ត្រូវបានផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ទើប WWF អនុវត្តន៍តាមយុទ្ធសាស្ត្រសមាហរណកម្ម ដើម្បីឆ្ពោះទៅសម្រេចគោលដៅការងាររបស់ខ្លួន។ WWF ខិតខំថែរក្សា ការពារធម្មជាតិក្នុងពិភពលោក ជួយដល់ប្រជាជន ឱ្យរស់នៅប្រកបដោយនិរន្តរភាព និងចាត់វិធានការដើម្បីប្រយុទ្ធប្រឆាំងនឹង ការប្រែប្រួលអាកាសធាតុ។

កម្មវិធី ជំនឿ និងគុណតម្លៃ របស់ WWF ដែលបានឧបត្ថម្ភសៀវភៅមគ្គុទ្ទេសក៏នេះឡើង ដើម្បីកៀរគរ ឱ្យមានការចូលរួមពីថ្នាក់ដឹកនាំមូលដ្ឋាន និងសហគមន៍ តាមបែបបទជំនឿអរូបិយ សាសនា និងវប្បធម៌ ព្រមទាំងគុណប្រយោជន៍របស់ពួកគេ។

មជ្ឈមណ្ឌលអង្គរសម្រាប់ការអភិរក្សជីវៈចម្រុះ (ACCB) ត្រូវបានបង្កើតឡើង និងប្រតិបត្តិការដោយសួនសត្វ អាល់វិតធឿស្សូម៊ុនស្ទឿ Allwetterzoo Münster។ ACCB គឺជាមជ្ឈមណ្ឌលអភិរក្សសត្វព្រៃមុនដំបូងគេបង្អស់មួយនៅប្រទេសកម្ពុជា ដែលមានទីតាំងនៅជើងភ្នំក្បាលស្ពាន ចម្ងាយប្រហែលជា ៥០គីឡូម៉ែត្រ ខាងជើងតំបន់អង្គរ ដែលជាបេតិកភណ្ឌពិភពលោកដ៏ល្បីល្បាញមួយ ទទួលស្គាល់ដោយអង្គការយូណេស្កូ។ ជារៀងរាល់ឆ្នាំ សត្វព្រៃរាប់រយក្បាលត្រូវបានស្តារនីតិសម្បទា ហើយលែងត្រឡប់ទៅក្នុងព្រៃធម្មជាតិវិញ (ប្រសិនបើអាច)។ លើសពីនេះទៀត ACCB បានអនុវត្តសកម្មភាពអប់រំបរិស្ថាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការគំរាមកំហែងនានាដែលប៉ះពាល់ដល់ប្រភេទសត្វព្រៃដែលរងគ្រោះជិតផុតពូជនៅប្រទេសកម្ពុជា។ សៀវភៅ **នីតិវិធីនៃការសង្គ្រោះសត្វព្រៃ ចាប់សត្វព្រៃ និងលែងសត្វព្រៃ** នេះត្រូវបានរៀបចំឡើងដើម្បីគាំទ្រ ពង្រឹងសមត្ថភាពដល់ព្រះសង្ឃពុទ្ធសាសនាដែលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចការពារ និងអភិរក្សសត្វព្រៃនៅប្រទេសកម្ពុជា។